00944876

**E299**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---


ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / 08 / 2013
ម៉ោង (Time/Heure): 15:25
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada


**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន**
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យូរ ឧត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣

ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: **សាធារណៈ អមដោយឧបសម្ព័ន្ធសម្ងាត់**

---

# សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកនៅសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

---

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Victor KOPPE
គង់ សំអុន
Jacques VERGÈS
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម

1. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើសុំរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") ស្នើសុំដាក់កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី[1] បណ្តឹងរបស់ជនរងគ្រោះ[2] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារសម្ភារៈពាក់ព័ន្ធ[3] (ជារួមហៅថា "ឯកសារ") និងប្រតិចារឹកសំណុំរឿង០០១ នៅចំពោះមុខអង្គជំនុំជម្រះ[4]។ មេធាវីការពារក្តី នួន ជា ("នួន ជា") និងមេធាវីការពារក្តី ខៀវ សំផន ("ខៀវ សំផន") ជំទាស់នឹងសំណើសុំនេះ[5]។

---

[1] សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ស្នើសុំឱ្យទទួលយកចម្លើយជាលាយលក្ខណ៍អក្សរផ្សេងៗជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ រួមបញ្ចូលទាំងកំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត កំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយសហព្រះរាជាអាជ្ញាក្នុងអំឡុងពេលការស៊ើបអង្កេតបឋម និងចម្លើយធ្វើឡើង ឬប្រមូលដោយ DC-Cam និងអង្គភាពដទៃផ្សេងទៀត។

[2] ផ្អែកតាមវិធានផ្ទៃក្នុង ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងមួយទៅសហព្រះរាជអាជ្ញាដើម្បីចោទប្រកាន់អំពីការប្រព្រឹត្តបទល្មើស។ ពាក្យបណ្តឹងបែបនេះ ត្រូវបានចាត់ទីតិវិធីដោយអង្គភាពគាំពារជនរងគ្រោះ និងត្រូវបានបញ្ជូនទៅសហព្រះរាជអាជ្ញា។ ពាក្យបណ្តឹងត្រូវរួមបញ្ចូលអត្តសញ្ញាណរបស់អ្នកប្តឹង កម្មវត្ថុនៃបណ្តឹង សេចក្តីសង្ខេបនៃបទល្មើសព្រហ្មទណ្ឌដែលត្រូវបានចោទប្រកាន់ ព័ត៌មានលម្អិតនៃសាក្សីសក្តានុពល និងភស្តុតាងណាមួយដែលអ្នកប្តឹងមាន (វិធាន ៤៩ នៃវិធានផ្ទៃក្នុង និងមាត្រា ២ នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមនៃជនរងគ្រោះ)។

[3] ដើម្បីអាចទទួលស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះត្រូវតែដាក់ពាក្យស្នើសុំទៅអង្គភាពជនរងគ្រោះ ដែលក្រោយមកបញ្ជូនពាក្យស្នើសុំនេះទៅសហចៅក្រមស៊ើបអង្កេត។ ពាក្យស្នើសុំត្រូវតែបញ្ជាក់អត្តសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណីឱ្យបានច្បាស់ និងបញ្ជាក់អំពីព្យសនកម្មដោយផ្ទាល់ខ្លួន ដែលជាផលលំបាកដោយផ្ទាល់ពីឧក្រិដ្ឋកម្មនេះ។ ដូចនេះ របាយការណ៍របស់អង្គភាពគាំពារជនរងគ្រោះ ភស្តុតាងអំពីព្យសនកម្មដែលខ្លួនទទួលរង ភស្តុតាងណាមួយដែលអ្នកប្តឹងមាន និងឯកសារសម្ភារៈផ្សេងទៀតដែលភ្ជាប់មកជាមួយ និង/ឬ ទម្រង់ផ្នែកនៃពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី (វិធាន២៣*ស្ទួន* នៃវិធានផ្ទៃក្នុង និងមាត្រា៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមនៃជនរងគ្រោះ)។

[4] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងស្តីអំពីការស្នើសុំឱ្យទទួលយកភស្តុតាងនៃកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារផ្សេងទៀត ឯកសារ E223/2/7 ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ ("សំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានកែសម្រួល") ឧបសម្ព័ន្ធសម្ងាត់បំផុត ១(ក) ឯកសារ E223/2/7.1, ឧបសម្ព័ន្ធសម្ងាត់ ក ឯកសារ E223/2/7/1.1។ សារណារបស់សហព្រះរាជអាជ្ញាអំពីឧបសម្ព័ន្ធទី ១២ និងទី ១៣ ដែលបានកែសម្រួលឡើងវិញក្នុងបញ្ជីឯកសារសម្រាប់សវនាការរបស់ខ្លួន អនុលោមតាមវិធាន៨០(៣) (កំណត់ហេតុស្តាប់ចម្លើយសាក្សី និងពាក្យបណ្តឹង) ឯកសារ E278 ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ ("សំណើសុំរបស់ក.ស.ពដែលត្រូវបានកែសម្រួល"), ឧបសម្ព័ន្ធ ១២ ឯកសារ E278.3 ("ឧបសម្ព័ន្ធ១២ដែលត្រូវបានកែសម្រួល"), ឧបសម្ព័ន្ធ ១៣ ឯកសារ E 278.4 ("ឧបសម្ព័ន្ធ១៣ ដែលត្រូវបាន

## ២. សាធារ

2. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានស្នើសុំដាក់កំណត់ហេតុស្តាប់ចម្លើយចំនួន ១.៨១៩ និងប្រតិចារឹកក្នុងសំណុំរឿង០០១ ចំនួន៦៩[6]។ នៅថ្ងៃជាមួយគ្នានេះដែរ សហមេធាវីនាំមុខបានស្នើសុំដាក់ឯកសារចំនួន ៨.១១០[7]។ នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ សហមេធាវីនាំមុខ បានកាត់បន្ថយចំនួនឯកសារដែលស្នើសុំ មកត្រឹមចំនួនឯកសារដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី

---

កែសម្រួល") *ដែលរួមបញ្ចូល*ឧបសម្ព័ន្ធ១១ - ប្រតិចារឹកសំណុំរឿង០០១ របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E9/31.1 ("ឧបសម្ព័ន្ធ១១")។ *សូមមើលផងដែរ* ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីជំទាស់របស់សហមេធាវីការពារក្តីចំពោះការទទួលយកកំណត់ហេតុសាក្សី ពាក្យបណ្តឹង និងប្រតិចារឹក ឯកសារ E277/1 ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ("ចម្លើយតបរបស់ក.ស.ព")។ សារណាតបរួមរបស់សហមេធាវីនាំមុខ ទៅនឹងសេចក្តីជំទាស់របស់មេធាវីការពារក្តីស្តីពីភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយ ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ ឯកសារ E277/2 ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ ("សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី")។

[5] ការឆ្លើយតបជាបឋមទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី និងប្រតិចារឹក ឯកសារ E96/8/1 ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("ចម្លើយតបជាបឋមរបស់ នួន ជា")។ សេចក្តីសន្និដ្ឋានអនុលោមតាមវិធាន ៩២ អំពីច្បាប់អនុវត្តលើការទទួលយកជាភ័ស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយ ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ អនុលោមតាមវិធាន៩២ ឯកសារ E277 ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ ("ចម្លើយតបរបស់ ខៀវ សំផន")។ ការជំទាស់ទៅនឹងសំណើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹក ឯកសារ E223/2/8 ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ("ចម្លើយតបរបស់ នួន ជា")។ ឧបសម្ព័ន្ធបន្ថែមពាក់ព័ន្ធនឹងការជំទាស់ទៅនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹកនានា ឯកសារ E223/2/8/1 ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ ("ចម្លើយតបបន្ថែមរបស់ នួន ជា") ឧបសម្ព័ន្ធ១ ឯកសារ E223/2/8/1.2, ឧបសម្ព័ន្ធ២ ឯកសារ E223/2/8/1.3, ឧបសម្ព័ន្ធ៣ ឯកសារ E223/2/8/1.1 (ជារួមហៅថា "ឧបសម្ព័ន្ធ ១-៣")។ សេចក្តីជំទាស់របស់លោក ខៀវ សំផន ទៅនឹងការដាក់បញ្ចូលក្នុងកិច្ចពិភាក្សានូវសក្ខីកម្មជាលាយលក្ខណ៍អក្សរមួយចំនួនដែលស្នើដោយសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ ឯកសារ E208/5 ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ("ចម្លើយតបបន្ថែមរបស់ ខៀវ សំផន"), ឧបសម្ព័ន្ធ១ ឯកសារ E208/5.1, ឧបសម្ព័ន្ធ២ ឯកសារ E208/5.2, ឧបសម្ព័ន្ធ៣ ឯកសារ E208/5.3, ឧបសម្ព័ន្ធ៤ ឯកសារ E208/5.4, ឧបសម្ព័ន្ធ៥ ឯកសារ E208/5.5, ឧបសម្ព័ន្ធ៦ ឯកសារ E208/5.6, ឧបសម្ព័ន្ធ៧ ឯកសារ E208/5.7 (ជារួមហៅថា "ឧបសម្ព័ន្ធ ១-៧")។

[6] បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់សវនាការស្របតាមវិធាន ៨០(៣) ឯកសារ E9/31 ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ១, ១៩-២១ ("បញ្ជីរបស់ក.ស.ព ចុះខែ មេសា ឆ្នាំ ២០១១") ឧបសម្ព័ន្ធ ១១ - ប្រតិចារឹកសំណុំរឿង០០១ របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E9/31.11, ឧបសម្ព័ន្ធ ១២ - សក្ខីកម្មរបស់សាក្សី ឯកសារ E9/31.12 ឧបសម្ព័ន្ធ ១៣ - បណ្តឹង ឯកសារ E9/31.13។

[7] បញ្ជីឯកសារ និងវត្ថុតាងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ឧបសម្ព័ន្ធ៧ និង៨) ឯកសារ E9/32 ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ១៣។

ចំនួន ៣.៨៦៦ នាក់ ដែលត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿង០០២[8]។ នៅក្នុងសេចក្តីសម្រេចលើកទីមួយស្តីពីភាពអាចទទួលយកបានភ័ស្តុតាងជាឯកសារ ដែលបានចេញនៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានទទួលយកឯកសារចំនួន ១៩៧ និងប្រតិចារិកក្នុងសំណុំរឿង០០១ចំនួន ៦ ដែលពាក់ព័ន្ធក្នុងការបង្ហាញភ័ស្តុតាងអំពីសាវតារប្រវត្តិសាស្ត្រ ព្រមទាំងអំពីរចនាសម្ព័ន្ធទំនាក់ទំនង និងរចនាសម្ព័ន្ធរដ្ឋបាល[9]។

3. នៅក្នុងសេចក្តីសម្រេចនៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ") អង្គជំនុំជម្រះ ដោយបានយោងទៅលើវិធាននីតិវិធីដែលបង្កើតនៅកម្រិតអន្តរជាតិ បានសម្រេចថា ផ្អែកលើលក្ខខណ្ឌមួយចំនួន កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ និងប្រតិចារិក ត្រូវបានទទួលយក ដោយមិនចាំបាច់ផ្តល់ឱកាសឲ្យតទល់គ្នា ជំនួសឲ្យការផ្តល់សក្ខីកម្មផ្ទាល់មាត់[10]។ អង្គជំនុំជម្រះបានណែនាំភាគីនានាឲ្យពិនិត្យ មើលបញ្ជីឯកសាររបស់ខ្លួនត្រឹមថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ អនុលោមតាមលក្ខណៈវិនិច្ឆ័យនៃភាពអាចទទួលយកបាន ដូចមានចែងនៅក្នុងសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ ដើម្បីបញ្ជាក់ពីគោលបំណងនៃភ័ស្តុតាងរបស់ឯកសារនីមួយៗឲ្យបានច្បាស់លាស់ ឬប្រភេទនៃឯកសារ (ជាពិសេសនៅពេលមូលហេតុជាក់លាក់នានាត្រូវបានលើកឡើងសម្រាប់ជាយុត្តិកម្មលើការទទួលយកកំណត់ហេតុទាំងឡាយ ដែលបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដោយមិនចាំបាច់ស្តាប់សក្ខីកម្មសាក្សីនៃកំណត់ហេតុទាំងនោះនៅក្នុងសវនាការ) ហើយភាគីត្រូវពិចារណាស្នើសុំដាក់តែចំនួនគំរូតំណាងមួយ នៃប្រភេទភ័ស្តុតាងនីមួយៗ នៅពេលដែល

---

[8] បញ្ជីឯកសារ និងភ័ស្តុតាងដែលត្រូវបានកែសម្រួលរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធនឹងចំណុចអង្គហេតុទាំងបួនដែលត្រូវធ្វើសវនាការនៅដំណាក់កាលដំបូង ឯកសារ E109/2 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។

[9] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងអង្គហេតុចំនួនពីរដែលត្រូវធ្វើសវនាការនៅដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ឯកសារ E185 ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ ("សេចក្តីសម្រេចស្តីពីក្រុមខណ្ឌឯកសារ") ឧបសម្ព័ន្ធ ក ឯកសារ E185.1 ទំព័រ១៩-៣៧, ៤១-៤៨ (ជាភាសាអង់គ្លេស) (ទទួលយកចម្លើយទាំងឡាយដែលធ្វើឡើង ដោយ DC-Cam និងស្ថាប័នផ្សេងទៀត, កំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត និងការស្តាប់ចម្លើយដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា)។

[10] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ") កថាខណ្ឌ ២០-៣៣ ផ្នែកសម្រេចសេចក្តី។

ភ័ស្តុតាងនេះមានចំនួនច្រើន ឬជាពិសេសមានភាពច្រំដែល[11]។ នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២ និងថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានស្នើសុំដាក់ឯកសារនានាដែលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទីមួយ និង ទីពីរ[12]។ នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញា បានដាក់បញ្ជីឯកសារ និងប្រតិចារឹកលើសពី ១.៥០០ ដែលដាក់បញ្ចូលដោយយោងលើឯកសារទាំងឡាយដែលស្នើសុំទាក់ទិននឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទីមួយ និងទីពីរ[13]។ សហមេធាវីនាំមុខ ក៏បានបង្ហាញថា ពួកគាត់លែងស្នើសុំដាក់បណ្តឹងរបស់ជនរងគ្រោះ

[11] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ៣៤-៣៦ ផ្នែកសេចក្តីសម្រេច។ ដើម្បីជាផលប្រយោជន៍នៃកិច្ចដំណើរការនីតិវិធីឱ្យបានឆាប់រហ័ស អង្គជំនុំជម្រះបានបញ្ជាក់ថា ភាគីត្រូវបានបញ្ជាក់ត្រឹមថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ អំពីឯកសារទាំងអស់ដែលខ្លួនស្នើសុំទាក់ទិននឹងសំណុំរឿង០០២/០១ (សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១ និងទី២ (ឯកសារ E208 និងឯកសារ E208/2) និងចម្លើយតបរបស់ជនជាប់ចោទ អៀង សារី (E208/1) ឯកសារ E208/3 ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ (“អនុស្សរណៈចុះខែ កក្កដា ឆ្នាំ ២០១២”) កថាខណ្ឌ៣)។

[12] សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទីមួយ ឯកសារ E208 ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២ (“សំណើសុំទាក់ទិននឹងដំណាក់កាលទីមួយ”)។ សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកចម្លើយសាក្សីនានាដែលទាក់ទងនឹងដំណាក់កាលទី២ នៃការជម្លៀសប្រជាជន និងបញ្ជាភ័ស្តុតាងផ្សេងទៀត ឯកសារ E208/2 ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២ (“សំណើសុំទាក់ទិននឹងដំណាក់កាលទី២”)។ *សូមមើលផងដែរ* ចម្លើយតបរបស់លោក អៀង សារី ទៅកាន់សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១ ឯកសារ E208/1 ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១២។

[13] សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក ជាមួយនឹងឧបសម្ព័ន្ធសម្គាត់ពី ១-១៦ ឯកសារ E96/8 ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ (“សំណើរបស់ក.ស.ព ខែ កក្កដា ឆ្នាំ ២០១២”) កថាខណ្ឌ៤, ៦, ៣៨។ ឧបសម្ព័ន្ធ ៩ ឯកសារ E96/8.10។ ក្រោយមក ខៀវ សំផន បានស្នើសុំអង្គជំនុំជម្រះឱ្យបង្គាប់សហព្រះរាជអាជ្ញាឱ្យកែសម្រួលបញ្ជីឯកសារដែលបានស្នើសុំ (មតិគាំទ្រសំណើលោក អៀង សារី E221 និងស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបង្គាប់ដល់សហព្រះរាជអាជ្ញាធ្វើការកែតម្រូវបញ្ជីសក្ខីកម្មជាលាយលក្ខណ៍អក្សរដែលសហព្រះរាជអាជ្ញាមានបំណងដាក់បញ្ចូលក្នុងការពិភាក្សាដេញដោល ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ឯកសារ E223 ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ៦-២២)។ សហព្រះរាជអាជ្ញាបានស្នើសុំជាថ្មីឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយទាំងអស់ដែលបានត្រូវកំណត់អត្តសញ្ញាណនៅក្នុងសំណើសុំរបស់ក.ស.ព ខែ កក្កដា ឆ្នាំ ២០១២ (ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន ស្នើសុំកែសម្រួលបញ្ជីភស្តុតាងជាក់លាក់ ឯកសារ E223/1 ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១២ (“សំណើសុំ ខែ កញ្ញា ឆ្នាំ ២០១២”))។

ណាមួយហើយ ប៉ុន្តែនៅតែស្នើសុំឱ្យទទួលយកឯកសារ ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ទាំងអស់ចំនួន ៣.៨៦៦ ដែលត្រូវបានប្រកាសទទួលស្គាល់នៅក្នុងសំណុំរឿង ០០២[14]។

4. នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ ដោយរួមបញ្ចូលការសម្លាប់អតីតមន្ត្រីសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ[15]។ ហេតុដូច្នេះ នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានបង្គាប់ឱ្យភាគីនានាបង្ហាញភស្តុតាងបន្ថែមទាំងអស់ដែលភាគីស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះទាក់ទិននឹងទួលពោធិ៍ជ្រៃ, ការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទីមួយ និងទីពីរ មិនឱ្យលើសពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១២[16]។ អង្គជំនុំជម្រះបានជូនដំណឹងបន្ថែមដល់សហព្រះរាជអាជ្ញាថា មានតែកំណត់ហេតុស្តាប់ចម្លើយទាំងឡាយណាដែលមានជាភាសាផ្លូវការ

---

[14] សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង E96/7 និងទៅនឹងអនុស្សរណៈ E208/3 ដោយរួមបញ្ចូលទាំងឧបសម្ព័ន្ធសម្ងាត់ទី១ និងទី២ ឯកសារ E208/4 ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ ("សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី") កថាខណ្ឌ ១៧ និងទំព័រ១៥ (លើកអំណះអំណាងក្នុងចំណោមទឡ្ហីករណ៍ផ្សេងទៀតថា "ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បង្កើតបានជាប្រភេទដាច់ដោយឡែកមួយនៃកំណត់ហេតុស្តាប់ចម្លើយ ដែលមិនអាចចាត់ទុកថាជាកំណត់ហេតុស្តាប់ចម្លើយសាក្សី និងតាមរយៈលក្ខណៈនៃកំណត់ហេតុនេះ មិនអាចស្ថិតក្រោមការកម្រិត *បឋម*ត្រឹមគំរូដែលតំណាងឱ្យកំណត់ហេតុស្តាប់ចម្លើយ")។

[15] សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5 ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ៣។ នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ បន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូល បដិសេធចោលដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះសាលាដំបូងជាថ្មីម្តងទៀត បានកំណត់វិសាលភាពនៃសំណុំរឿង ០០២/០១ ត្រឹមបទចោទទាំងឡាយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចជាការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទីមួយ និងទីពីរ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលនោះ និងការសម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ (ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ២-៤។ *សូមមើលផងដែរ* សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E284 ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣)។

[16] សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភស្តុតាងគាំទ្រ (ឯកសារ E223) ឯកសារ E223/2 ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ("អនុស្សរណៈខែ តុលា ឆ្នាំ ២០១២") កថាខណ្ឌ៤។

ទាំងអស់ប៉ុណ្ណោះ និងត្រូវយកមកពិចារណា។ សហព្រះរាជអាជ្ញាត្រូវបានណែនាំឱ្យជូនដំណឹងដល់អង្គជំនុំជម្រះ និងភាគីនានា ឱ្យបានឆាប់រហ័សបំផុត ប្រសិនបើកំណត់ហេតុស្តាប់ចម្លើយមួយចំនួនដែលត្រូវបានលើកឡើងនៅក្នុងសំណើសុំរបស់សហព្រះរាជអាជ្ញានៅខែ កក្កដា ឆ្នាំ ២០១២ លែងត្រូវបានស្នើសុំដាក់បញ្ចូលទៀតហើយនោះ[17]។ អង្គជំនុំជម្រះក៏បានបង្គាប់សហមេធាវីនាំមុខឱ្យកំណត់គំរូដែលតំណាងឱ្យកំណត់ហេតុស្តាប់ចម្លើយទាក់ទិននឹងប្រធានបទទាំងអស់ដែលត្រូវធ្វើសវនាការ និងមានជាភាសាផ្លូវការទាំងអស់ មិនឱ្យលើសពីថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣[18]។ ពេលវេលាកំណត់សម្រាប់ការជំទាស់ទៅនឹងកំណត់ហេតុដែលស្នើសុំ គឺត្រឹមថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣[19]។ នួន ជា បានដាក់ចម្លើយតបជាបឋមនៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២[20]។

5. នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានស្នើសុំដាក់ភស្តុតាងបន្ថែមដែលខ្លួនចាត់ទុកថាពាក់ព័ន្ធនឹងការសម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ និងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទីមួយ និងទីពីរ ដោយបដិសេធការដាក់បញ្ចូលកំណត់ហេតុស្តាប់ចម្លើយមួយចំនួន ដើម្បីជៀសវាង "ការច្រំដែល" ជាមួយនឹងសំណើសុំពីមុន[21]។ នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ ដោយពិចារណាលើលក្ខណៈវិនិច្ឆ័យនៃការទទួលយកបាន ដែលអនុវត្តចំពោះកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក នៅក្នុងសេចក្តីសម្រេចទីពីររបស់ខ្លួនទាក់ទិននឹងភស្តុតាងឯកសារ អង្គជំនុំជម្រះបានទទួលយកប្រតិចារឹកក្នុងសំណុំរឿង០០១ ចំនួនដប់ និងកំណត់ហេតុស្តាប់ចម្លើយចំនួន

---

[17] អនុស្សរណៈ ចុះខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ៩។ ចម្លើយតបទៅនឹងសំណើ E246 និង E185/1/1 និងសំណើផ្សេងៗមួយចំនួនពាក់ព័ន្ធនឹងឯកសារ និងពេលវេលាកំណត់ ឯកសារ E246/1 ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ ("អនុស្សរណៈចុះខែ កុម្ភៈ ឆ្នាំ ២០១៣") កថាខណ្ឌ ៣។

[18] អនុស្សរណៈចុះខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ១២-១៣។

[19] អនុស្សរណៈចុះខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ១៤។ អនុស្សរណៈចុះខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ១។

[20] ចម្លើយតបជាបឋមរបស់ នួន ជា។ *សូមមើលផងដែរ* សារណារបស់ អៀង សារី ចូលរួមជាមួយការឆ្លើយតបជាបឋមរបស់ នួន ជា ទៅនឹងសេចក្តីស្នើបន្ថែមរបស់សហព្រះរាជអាជ្ញា សុំដាក់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/8/2 ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១២។

[21] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង សុំឱ្យបញ្ជាក់ឯកសារបន្ថែមដែលពាក់ព័ន្ធនឹងវគ្គសវនាការស្តីពីការជម្លៀសប្រជាជន និងទួលពោធិ៍ជ្រៃ និងញត្តិស្នើសុំកំណត់កាលវិភាគសម្រាប់សវនាការដេញដោលលើឯកសារ ឯកសារ E223/2/1 ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("សំណើសុំ ខែ វិច្ឆិកា ឆ្នាំ ២០១២") កថាខណ្ឌ ៦-៧។

ពីរ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា ដោយចាត់ទុកថាជាភស្តុតាងនៃបញ្ហានានា មិនមែនជាភស្តុតាងនៃអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់នោះទេ[22]។

6. សហមេធាវីនាំមុខបានដាក់បញ្ជីមួយដែលត្រូវបានកែសម្រួល ដែលមានឯកសារចំនួន ៥២០ នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣[23]។ នៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ ខៀវ សំផន បានដាក់សារណាស្តីពីបទដ្ឋានគតិយុត្តិ ដែលគ្រប់គ្រងទៅលើការទទួលយកឯកសារ ជំនួសឲ្យការផ្តល់សក្ខីកម្មផ្ទាល់មាត់[24]។ នៅថ្ងៃជាមួយគ្នានេះ សហព្រះរាជអាជ្ញាបានដាក់ស្នើបញ្ជីកែសម្រួលមួយដែលមានកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកចំនួន ១,១០៩ ដោយបង្ហាញភស្តុតាងដែលមានពាក់ព័ន្ធទៅនឹងភស្តុតាងនៃអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់[25]។ នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ នួន ជា និង ខៀវ សំផន បានឆ្លើយតបទៅនឹងសារណានេះ[26]។ នួន ជា បានដាក់សេចក្តីជំទាស់បន្ថែមនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣[27]។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ បានដាក់ចម្លើយតបរួមទៅនឹងសេចក្តីជំទាស់របស់មេធាវីការពារក្តីទាំងអស់នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ និងថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣[28]។

---

[22] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត ឯកសារ E185/1 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ ("សេចក្តីសម្រេច ខែ ធ្នូ ឆ្នាំ ២០១២") កថាខណ្ឌ១០, ១៧ និងឧបសម្ព័ន្ធ គ (E185/1.3) ទំព័រ ២៥, ៤៣, ៩៤-៩៥។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ១១។

[23] ឯកសារចំនួន ៥៦៦ ដែលមានពីមុននៅក្នុងឧបសម្ព័ន្ធ ១(ក) និង ១ នៃសំណើសុំដែលត្រូវកែសម្រួលរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលបានកត់សម្គាល់នៅក្នុងសារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឯកសារចំនួន ៤៦ គឺជាសំណៅបកប្រែជាភាសាបារាំងនៃកំណត់ហេតុស្តាប់ចម្លើយដែលត្រូវបានស្នើសុំ។

[24] ចម្លើយតបរបស់ ខៀវ សំផន។

[25] សហព្រះរាជអាជ្ញាបានស្នើសុំដាក់កំណត់ហេតុស្តាប់ចម្លើយចំនួន ៨៧៤ នៅក្នុងឧបសម្ព័ន្ធ ១២ ដែលត្រូវបានកែសម្រួល (ឯកសារ E278.3 រួមបញ្ចូលកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ៦៥០ ដែលក.ស.ព មិនបានស្នើសុំអ្នកទាំងនោះមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១ និងកំណត់ហេតុស្តាប់ចម្លើយចំនួន ១១ របស់សាក្សីដែលទទួលមរណភាព), បណ្តឹងចំនួន ១៦៦ នៅក្នុងឧបសម្ព័ន្ធ១៣ ដែលត្រូវបានកែសម្រួល (E278.4) និងប្រតិចារឹកចំនួន ៦៩ នៅក្នុងឧបសម្ព័ន្ធ ១១ (E9/31)។

[26] ចម្លើយតបរបស់ នួន ជា។ ចម្លើយតបបន្ថែមរបស់ ខៀវ សំផន។

[27] ចម្លើយតបបន្ថែមរបស់ នួន ជា។

[28] ចម្លើយតបរបស់ ក.ស.ព។ សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

7. នៅចន្លោះថ្ងៃទី ០៦ និងទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីអំពីសាក្សីនានាដែលត្រូវបានស្នើសុំនាពេលកន្លងមក ហើយដែលអង្គជំនុំជម្រះនឹងមិនកោះហៅនៅក្នុងសំណុំរឿង ០០២/០១[29]។ នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានបើកកិច្ចប្រជុំរៀបចំសវនាការជាចុងក្រោយនៅក្នុងសំណុំរឿង០០២/០១ ដើម្បីពិភាក្សាបញ្ហានៅសេសសល់ ដោយរួមបញ្ចូលទាំងសាក្សីនៅសល់ដែលនឹងត្រូវកោះហៅ និងភស្តុតាងដែលនឹងត្រូវទទួលយក[30]។ នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ នួន ជា បានដាក់សេចក្តីជំទាស់បន្ថែមទាក់ទិននឹងការទទួលយកភស្តុតាងពាក់ព័ន្ធនឹងការសម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។ ភស្តុតាងនេះមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់បុគ្គល ដែលមិនត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ហើយថែមទាំងបានស្នើសុំឲ្យកោះហៅសាក្សីចំនួនប្រាំមួយរូប[31]។ នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានឆ្លើយតបទាក់ទិនតែនឹងសារណារបស់ នួន ជា ស្តីពីភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយ ជំនួសឲ្យការផ្តល់សក្ខីកម្មផ្ទាល់មាត់[32]។ នួន ជា បានដាក់សារណាតបនៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៣[33]។

8. នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យមេធាវីការពារក្តីបញ្ជាក់អំពីការជំទាស់របស់ខ្លួនទាក់ទិននឹងកំណត់ហេតុស្តាប់ចម្លើយ ដែលមេធាវីការពារក្តីយកមកប្រើប្រាស់ក្នុង

---

29 កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើឯកសារជាលើកចុងក្រោយ និងសវនាការផ្សេងៗនៅក្នុងសំណុំរឿង ០០២/០១ សម្រាប់ការសួរសំណួរទៅជនជាប់ចោទ និងចម្លើយតបទៅនឹងសំណើ E263 និងសំណើ E288/1, ឯកសារ E288/1/1 ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣។ អ៊ីម៉ែលរបស់លោកស្រី Susan LAMB ដែលមានកម្មវត្ថុ៖ ការជូនដំណឹងជាមុនអំពីសាក្សីបន្ថែមដែលត្រូវកោះហៅនៅក្នុងសំណុំរឿង០០២/០១ ដើម្បីឆ្លើយតបទៅនឹងសំណើសុំរបស់សាក្សីនៅក្នុងកិច្ចប្រជុំរៀបចំសវនាការជាចុងក្រោយ ឯកសារ E292 ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ II៖ បុគ្គលនានាដែលបានស្នើសុំដោយភាគីទាក់ទិននឹងសំណុំរឿង០០២/០១ ប៉ុន្តែជាចុងក្រោយមិនត្រូវបានស្តាប់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះទេ (មន្ត្រីច្បាប់ជាន់ខ្ពស់ បានផ្ញើជូនសំណៅចម្លងជាមុនដើម្បីជាការជូនដំណឹង ជូនដល់ភាគីនានានៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣)។

30 កិច្ចប្រជុំរៀបចំសវនាការ ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣។

31 សំណើបន្ទាន់ស្នើសុំកោះហៅសាក្សីសំខាន់ៗទាក់ទិននឹងទួលពោធិ៍ជ្រៃ ឯកសារ E291 ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ (“សំណើរបស់ នួន ជា ទាក់ទិននឹងទួលពោធិ៍ជ្រៃ”)។

32 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង “សំណើជាបន្ទាន់” របស់ នួន ជា សុំឲ្យកោះហៅសាក្សីគន្លឹះនានា ទាក់ទងនឹងទួលពោធិ៍ជ្រៃ ឯកសារ E291/1 ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣ (“សំណើរបស់ ក.ស.ព ទាក់ទិននឹងទួលពោធិ៍ជ្រៃ”)។

33 ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើបន្ទាន់ស្នើសុំកោះហៅសាក្សីសំខាន់ៗទាក់ទិននឹងទួលពោធិ៍ជ្រៃ ឯកសារ E291/1/1 ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៣ (“ការឆ្លើយតបរបស់ នួន ជា ទាក់ទិននឹងទួលពោធិ៍ជ្រៃ”)។

00944885



ការសួរដេញដោលសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ[34]។ ខៀវ សំផន និង នួន ជា បានបញ្ជាក់អំពីសេចក្ដីជំទាស់ពីមុនរបស់ខ្លួនទៅនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយ ជំនួសឱ្យការផ្ដល់សក្ខីកម្មផ្ទាល់មាត់[35]។ បន្ថែមពីលើនេះទៀត នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ នួន ជា បានស្នើសុំអង្គជំនុំជម្រះឱ្យកោះហៅសាក្សីចំនួន១១១ រូប ដែលបានផ្ដល់ចម្លើយទាក់ទិននឹងការកំណត់មុខសញ្ញាមន្ត្រីសាធារណរដ្ឋខ្មែរ នៅក្នុងករណីដែលកំណត់ហេតុស្ដាប់ចម្លើយរបស់ពួកគេត្រូវបានទទួលយក[36]។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានឆ្លើយតបនឹងសំណើសុំនេះ[37]។ នៅថ្ងៃនោះដែរ អង្គជំនុំជម្រះបានបដិសេធចោលសំណើសុំឱ្យកោះហៅសាក្សីទាំង ១១១ រូបនោះ ដោយជូនដំណឹងដល់ភាគីនានាថា សម្អាងហេតុរបស់ខ្លួននឹងចេញនៅពេលក្រោយ[38]។

## ៣. សារណា

### ៣.១ សារណាពាក់ព័ន្ធនឹងសំណើកែសម្រួលរបស់ ក.ស.ព និងដើមបណ្ដឹងរដ្ឋប្បវេណី

9. នៅក្នុងសំណើកែសម្រួលរបស់ ក.ស.ព សហព្រះរាជអាជ្ញាបានស្នើសុំដាក់កំណត់ហេតុស្ដាប់ចម្លើយសាក្សី និងប្រតិចារឹក ចំនួន ១,១០៩ ដែលត្រូវបានអះអាងថាបានបញ្ជាក់ និងគួរឱ្យជឿជាក់ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ផ្នែកអង្គហេតុនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ និង ពាក់ព័ន្ធទៅនឹងទីកន្លែងឧក្រិដ្ឋកម្មទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយ និងគោលនយោបាយនានារបស់កម្ពុជាប្រជាធិបតេយ្យ។ សហព្រះរាជអាជ្ញាលើកឡើងថា ទោះបីជាយ៉ាងណាក៏ដោយ កំណត់ហេតុស្ដាប់ចម្លើយ សាក្សីមួយចំនួន ដែលពាក់ព័ន្ធនឹងអង្គហេតុនានានៅក្រៅពីវិសាលភាពនៃសំណុំរឿង ០០២/០១ មានសារៈសំខាន់ណាស់ដើម្បីអនុវត្តកាតព្វកិច្ចក្នុងការស្វែងរកភស្តុតាង ទាក់ទិននឹងគោល

---

[34] ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៦១-៦២ (ជាភាសាអង់គ្លេស)។

[35] ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៦២-៦៧ (ជាភាសាអង់គ្លេស)។ សំណើលើកទី៦ និងចុងក្រោយសុំកោះហៅសាក្សី TCW-223 ឯកសារ E236/5/1/1 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៣ ("សំណើសុំរបស់ នួនជា ទាក់ទិននឹងសាក្សី TCW-223") កថាខណ្ឌ ១៧-២១។

[36] ប្រតិចារឹក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៥១-៥៤, ៥៩-៦០ (ជាភាសាអង់គ្លេស)។ សូមមើលផងដែរ សំណើសុំកោះហៅសាក្សីពាក់ព័ន្ធនឹងគោលនយោបាយដែលត្រូវបានចោទប្រកាន់អំពីការកំណត់មុខសញ្ញាមន្ត្រីសាធារណរដ្ឋខ្មែរ, ឯកសារ E291/2 ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣ ("សំណើសុំកោះហៅរបស់ នួនជា")។

[37] ប្រតិចារឹក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៥៤-៥៨ (ជាភាសាអង់គ្លេស) (សហព្រះរាជអាជ្ញា), ទំព័រ ៥៨-៥៩ (ជាភាសាអង់គ្លេស) (សហមេធាវីនាំមុខ)។

[38] ប្រតិចារឹក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៦៧-៦៨ (ជាភាសាអង់គ្លេស)។

នយោបាយសហឧក្រិដ្ឋកម្មរួម និងធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[39]។ សហព្រះរាជអាជ្ញាចង្អុលបង្ហាញថា កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះ មិនត្រូវបានស្នើឡើងជាភស្តុតាងអំពីអំពើ ឬការប្រព្រឹត្តរបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់ឡើយ ដូច្នេះការទទួលយកកំណត់ហេតុស្តាប់ចម្លើយទាំងនេះ ដោយគ្មានការសួរដេញដោល មិនត្រូវបានច្រានចោលជាមុនឡើយ[40]។ ទោះបីជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាបានស្នើឱ្យកោសល្យុបព័ត៌មានទាក់ទិននឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ពីក្នុងកំណត់ហេតុស្តាប់ចម្លើយចំនួន ២២០[41]។

10. សហព្រះរាជអាជ្ញាអះអាងទៀតថា បទដ្ឋានដែលបានកំណត់នៅក្នុងសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ បានសម្រួលវិធានស្តីពីនីតិវិធីអន្តរជាតិពាក់ព័ន្ធនឹងការទទួលយកចម្លើយរបស់សាក្សីឱ្យស្របជាមួយនឹងបរិបទរបស់ អ.វ.ត.ក ហើយត្រូវបកស្រាយបទដ្ឋាននេះឱ្យបានតឹងរ៉ឹង[42]។ សហព្រះរាជអាជ្ញាលើកឡើងថា ការពិចារណាហួសពីថាតើកំណត់ហេតុស្តាប់ចម្លើយផ្តល់ភស្តុតាងអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់ គួរតែត្រូវបានយកមកពិចារណាក្នុងការកំណត់អំពីទម្ងន់ដែលមាននៅក្នុងភស្តុតាង មិនមែនក្នុងការសម្រេចអំពីភាពអាចទទួលយកបាននោះទេ[43]។ ពួកគាត់ អះអាងថា មេធាវីការពារក្តីបានលះបង់ការជំទាស់របស់ខ្លួនដោយប្រយោល ចំពោះការទទួលយកកំណត់ហេតុស្តាប់ចម្លើយមួយចំនួន ដែលផ្តល់ភស្តុតាងអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់ ដោយប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយទាំងនេះក្នុងអំឡុងពេលសួរសំណួរទៅសាក្សីនានា។ សហព្រះរាជអាជ្ញាស្នើឱ្យអង្គជំនុំជម្រះពិចារណាលើបញ្ហានេះនៅក្នុងការសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយសាក្សី[44]។ ទោះបីជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាស្នើឱ្យអង្គជំនុំជម្រះពិចារណាទៅលើការស្តាប់សក្ខីកម្ម

---

[39] សំណើរបស់ ក.ស.ព ខែកក្កដា ឆ្នាំ២០១២ កថាខណ្ឌ ៣០-៣៤, សំណើរបស់ ក.ស.ព ដែលត្រូវបានកែសម្រួល កថាខណ្ឌ ២៨-៣០។ ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៣១-៤៤, ៦៩-៧០, ៧៣។ សូមមើលផងដែរ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទួលពោធិ៍ជ្រៃ កថាខណ្ឌ ៧-៨។

[40] ចម្លើយតបរបស់ ក.ស.ព ខែ កក្កដា ឆ្នាំ ២០១២ កថាខណ្ឌ ២, ១៥-១៧។ ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ២៨-៣០។

[41] សំណើរបស់ ក.ស.ព ដែលត្រូវបានកែសម្រួល កថាខណ្ឌ ៤-៥, ៣២-៣៣។ ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ២១, ២៤, ៦៤។ សូមមើលផងដែរ កិច្ចប្រជុំរៀបចំសវនាការ ទំព័រ ៨៦-៨៧។

[42] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ២, ១៣-២៧, ៦៣-៦៨, ៧៤-៧៦។ សូមមើលផងដែរ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទួលពោធិ៍ជ្រៃ កថាខណ្ឌ ៩។

[43] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទួលពោធិ៍ជ្រៃ កថាខណ្ឌ ៥។

[44] ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៦១-៦២ (ជាភាសាអង់គ្លេស)។

សាក្សីទាំងនោះ ដែលចម្លើយរបស់ពួកគាត់ផ្តល់ភ័ស្តុតាងអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ[45]។ លើសពីនេះទៀត សហព្រះរាជអាជ្ញាអះអាងថា កំណត់ហេតុស្តាប់ចម្លើយទាំងអស់របស់សាក្សីណាដែលបានស្លាប់ទៅហើយនោះ គួរតែត្រូវបានទទួលយកដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ ដោយមិនគិតអំពីថាតើ កំណត់ហេតុស្តាប់ចម្លើយទាំងនោះមានបង្ហាញអំពីភ័ស្តុតាងនៃអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់ ឬយ៉ាងណានោះឡើយ[46]។ ចុងក្រោយ សហព្រះរាជអាជ្ញាបានកំណត់អត្តសញ្ញាណ កំណត់ហេតុស្តាប់ចម្លើយនានារបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដោយស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងឡាយណាដែលមិនទាន់ត្រូវបានទទួលយកនៅចំពោះមុខអង្គជំនុំជម្រះ[47]។

11. សហមេធាវីនាំមុខស្នើឡើងនូវកំណត់ហេតុស្តាប់ចម្លើយចំនួន ៥២០ ដែលរួមទាំងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងសម្ភារៈឯកសារដែលពាក់ព័ន្ធ ហើយដែលត្រូវបានអះអាងថា បានបញ្ជាក់ និងមានការពាក់ព័ន្ធ។ ប៉ុន្តែសហមេធាវីនាំមុខលើកឡើងថា ពុំមានសម្ភារៈឯកសារណាមួយ ត្រូវបានស្នើឡើងក្នុងគោលបំណងផ្តល់ភ័ស្តុតាងអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដូចដែលបានចោទប្រកាន់ឡើយ[48]។ ពួកគាត់លើកឡើងថា ពួកគាត់មិនអាចញែកឱ្យឃើញភាពខុសគ្នារវាងផ្នែកនៃកំណត់ហេតុដែលថាអាចទទួលយកបាន និងផ្នែកដែលមិនអាចទទួលយកបានឡើយ ទាល់តែការជំទាស់តវ៉ារបស់មេធាវីការពារក្តីត្រូវបានដោះស្រាយរួចសិន។ នៅគ្រប់ករណីទាំងអស់ ពួកគាត់អះអាងថា ពុំមានភ័ស្តុតាងណាមួយគួរតែត្រូវបានដកចេញទាំងស្រុងឡើយ ដោយផ្អែកលើមូលដ្ឋានដែលថា មានតែផ្នែកមួយចំនួននៃកំណត់ហេតុស្តាប់ចម្លើយប៉ុណ្ណោះត្រូវបានទទួលយកនោះ[49]។ ទោះបីជាយ៉ាងណាក៏ដោយ សហមេធាវីនាំមុខស្នើឱ្យអង្គជំនុំជម្រះស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីណាដែលសក្ខីកម្មរបស់ពួកគាត់ផ្តល់ភ័ស្តុតាងអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់

---

[45] សំណើរបស់ ក.ស.ព ដែលត្រូវបានកែសម្រួល កថាខណ្ឌ ៣៤-៣៨, ៤០-៤១។ សូមមើលផងដែរ កិច្ចប្រជុំរៀបចំ សវនាការ ទំព័រ ៨៦-៨៧។

[46] សំណើរបស់ ក.ស.ព ដែលត្រូវបានកែសម្រួល កថាខណ្ឌ ៥, ២០។ ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៥៨, ៧១។

[47] សំណើរបស់ ក.ស.ព ដែលត្រូវបានកែសម្រួល កថាខណ្ឌ ២, ៥។

[48] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៩-២៣, ២៨, ៣៤-៤១។ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានកែសម្រួល កថាខណ្ឌ៩។ សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២៦-៣០។

[49] សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៣១-៣៥។

តាមសំណើរបស់មេធាវីការពារក្តី[50]។ លើសពីនេះទៀត សហមេធាវីនាំមុខលើកឡើងថា ការពិនិត្យឡើងវិញលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ក្នុងអំឡុងដំណាក់កាលស៊ើបអង្កេត បង្ហាញឱ្យឃើញអំពីភាពការអាចជឿជាក់បាន *ជាបឋម* នៃពាក្យសុំទាំងនោះ[51]។ ជាចុងក្រោយ សហមេធាវីនាំមុខអះអាងថា ការជំទាស់របស់មេធាវីការពារក្តីត្រូវបានដាក់មិនទាន់ពេលវេលា និងខ្វះភាពជាក់លាក់[52]។

12. នួន ជា លើកឡើងថា នៅពេលធ្វើការសម្រេចថាតើកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកនានាអាចត្រូវបានទទួលយក ឬមិនត្រូវទទួលយកជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់នោះ អង្គជំនុំជម្រះបានអនុម័តលក្ខណៈវិនិច្ឆ័យដែលបានកំណត់នៅក្នុងវិធាន ៩២ស្ទួននៃតុលាការ ICTY ដោយគ្មានការកម្រិតដូច្នេះអនុលោមតាមយុត្តិសាស្រ្ត និងវិធាននានារបស់តុលាការមិនអចិន្ត្រៃយ៍ តម្រូវឱ្យសាក្សីធ្វើការបញ្ជាក់ពីភាពត្រឹមត្រូវនៃចម្លើយរបស់ខ្លួន ពិចារណាថាតើកំណត់ហេតុស្តាប់ចម្លើយផ្តល់នូវភស្តុតាងអំពីអំពើល្មើសដែល "នៅជិតបំផុតនឹងជនជាប់ចោទ" ឬពាក់ព័ន្ធនឹង "បញ្ហាចម្រូងចម្រាស" និងដកចេញនូវកំណត់ហេតុស្តាប់ចម្លើយដែលរួមមានភស្តុតាងអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់ និង "ភស្តុតាងដែលនៅជិតនឹងជនជាប់ចោទ" ទោះបីជាពាក់ព័ន្ធផងដែរទៅនឹងគោលបំណងផ្សេងទៀតក៏ដោយ[53]។ នួន ជា លើកឡើងថា កំណត់ហេតុស្តាប់ចម្លើយនានាមិនមានលក្ខណៈគ្រប់គ្រាន់ទៅនឹងសក្ខីកម្មផ្ទាល់មាត់នៅចំពោះមុខអង្គជំនុំជម្រះទេ និងគួរតែដកចេញដោយផ្អែកលើមូលដ្ឋាននេះ[54]។ នួន ជា អះអាងថា ចំនួននៃកំណត់ហេតុស្តាប់ចម្លើយដែលបានស្នើឡើងមានចំនួនច្រើនពេក ហើយថា សហព្រះរាជអាជ្ញាខកខានមិនបានធ្វើការកាត់បន្ថយឱ្យបានគ្រប់គ្រាន់ និងឱ្យបានទាន់ពេលវេលា ហើយថា កំណត់ហេតុស្តាប់ចម្លើយដែលបានស្នើឡើងភាគច្រើនមានភាពពាក់ព័ន្ធតិច

---

[50] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៤៨។

[51] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២-៣, ១៤, ២៤-២៧។ សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៨-២៥។

[52] សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២, ១១-១៧។

[53] ចម្លើយតបបឋមរបស់ នួន ជា កថាខណ្ឌ ៥-៣៦, ៤០។ ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៧-១៤, ៣១, ៣៤-៣៩, ៤៤។ ចម្លើយតបបន្ថែមរបស់ នួន ជា កថាខណ្ឌ ៤-៦, ៩ ឧបសម្ព័ន្ធ ១-៣។ *សូមមើលផងដែរ* សំណើរបស់ នួន ជា ទាក់ទងនឹងទូលពោធិ៍ជ្រៃ កថាខណ្ឌ ៣៦។

[54] ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ២៤-៣០។ *សូមមើលផងដែរ* សំណើរបស់ នួន ជា ទាក់ទិននឹងទូលពោធិ៍ជ្រៃ កថាខណ្ឌ ៨, ៣៦។ សារណាតបរបស់ នួន ជា ទាក់ទិននឹងទូលពោធិ៍ជ្រៃ កថាខណ្ឌ ៣-៦, ៨។

តួច[55]។ នួន ជា អះអាងផងដែរថា គោលដៅនៃស្ថាប័នមជ្ឈមណ្ឌលឯកសារកម្ពុជា និងភាពគួរឱ្យជឿជាក់បាននៃកំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") និងស្ថាប័នក្រៅពី អ.វ.ត.ក គួរតែនាំឱ្យមានការដកចេញនូវឯកសារទាំងនោះ។ លើសពីនេះទៀត ពួកគាត់អះអាងថា ការទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់ ក.ស.ព និងប្រតិចារឹកសំណុំរឿង ០០១ នឹងរំលោភទៅលើគោលការណ៍សមភាពនៃមធ្យោបាយក្នុងការតទល់ក្តីគ្នា ហើយការទទួលយកប្រតិចារឹកសំណុំរឿង ០០១ នឹងរារាំងសមត្ថភាពរបស់អង្គជំនុំជម្រះមិនឱ្យមានភាពមិនលម្អៀងនៅក្នុងសំណុំរឿង ០០២[56]។

13. ខៀវ សំផន អះអាងថា កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងអស់ដែលទាក់ទិនទៅនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ឬ "បញ្ហាចម្រូងចម្រាស" រវាងភាគី ត្រូវតែដកចេញនៅពេលដែលពុំមានការផ្តល់ឱកាសឱ្យមានការសួរដេញដោល[57]។ ខៀវ សំផន កំណត់ "បញ្ហាចម្រូងចម្រាស" ថាជារចនាសម្ព័ន្ធ អត្ថិភាព និងគោលនយោបាយនៃសហឧក្រិដ្ឋកម្មរួម លក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការផ្លាស់ទីលំនៅប្រជាជន[58]។ ខៀវ សំផន ក៏ជំទាស់ផងដែរទៅនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយនានានៅក្រៅពីវិសាលភាពនៃសំណុំរឿង០០២/០១ កំណត់ហេតុស្តាប់ចម្លើយដែលពុំមានការបញ្ជាក់ កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលពុំមានការថតខ្សែអាត់សំឡេងនៅក្នុងសំណុំរឿង និងកំណត់ហេតុស្តាប់ចម្លើយទាំងអស់ដែលធ្វើឡើងដោយស្ថាប័នក្រៅពី អ.វ.ត.ក[59]។

14. ក្នុងការឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ទាំង នួន ជា និង ខៀវ សំផន បានបញ្ជាក់អំពីការជំទាស់របស់ខ្លួនទៅនឹងការទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរ ដោយអះអាងថា

---

[55] ចម្លើយតបបឋមរបស់ នួន ជា កថាខណ្ឌ ៣៧-៣៩។ ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ១៥, ១៧-២៣។

[56] ចម្លើយតបបឋមរបស់ នួន ជា កថាខណ្ឌ ៤០-៤៦។ ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៤០-៤២, ៤៥-៥២។

[57] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១៤-១៧, ៣៧, ៤៣-៤៥។ ចម្លើយតបបឋមរបស់ ខៀវ សំផន កថាខណ្ឌ ១៧-២៣, ៤៣ ឧបសម្ព័ន្ធ ១-៧។ *សូមមើលផងដែរ* កិច្ចប្រជុំរៀបចំសវនាការ ទំព័រ ៨៥ (ជាភាសាអង់គ្លេស)។

[58] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១៨-៤៣។ ចម្លើយតបបន្ថែមរបស់ ខៀវ សំផន កថាខណ្ឌ ២៤-២៦, ៤៣។

[59] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៣៤-៤៥។ ចម្លើយតបបន្ថែមរបស់ ខៀវ សំផន កថាខណ្ឌ ១៤, ២៧-៤១, ៤៣ ឧបសម្ព័ន្ធ ១-៧។

ការប្រើប្រាស់កំណត់ហេតុទាំងនេះក្នុងអំឡុងការសួរដេញដោលសាក្សីពីសំណាក់មេធាវីការពារក្តីនោះ ពុំមានពាក់ព័ន្ធទៅនឹងការទទួលយកកំណត់ហេតុទាំងនេះ ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ឡើយ[60]។

## ៣.២ សារណាអំពី "សំណើរបស់ នួន ជា ស្នើសុំកោះហៅសាក្សីពាក់ព័ន្ធនឹងគោលនយោបាយដូចបានចោទប្រកាន់ស្តីពីការកំណត់គោលដៅមន្ត្រីសាធារណរដ្ឋខ្មែរ"

15. នួន ជា បានលើកឡើងថា ផ្អែកលើមូលដ្ឋានមួយផ្នែកនៃភាពផ្ទុយគ្នានៅក្នុងភស្តុតាងរបស់សាក្សីផ្សេងៗទៀតនៅចំពោះមុខអង្គជំនុំជម្រះ កំណត់ហេតុស្តាប់ចម្លើយពាក់ព័ន្ធនឹងការកំណត់គោលដៅលើមន្ត្រីសាធារណរដ្ឋខ្មែរ មានលក្ខណៈពុំអាចជឿទុកចិត្តបានជាលក្ខណៈប្រព័ន្ធ និងមិនបានបញ្ជាក់បង្ហាញអំពីទម្រង់នៃការកាប់សម្លាប់រង្គាលដែលបង្ហាញជាគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យឡើយ[61]។ ម្យ៉ាងវិញទៀត នួន ជា បានលើកឡើងថា ខ្លួនកំពុងរង់ចាំអង្គជំនុំជម្រះជូនដំណឹងដល់ភាគីអំពីកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរដែលនឹងអាចទទួលយកបាននោះ ហើយដូច្នេះ ពាក្យសុំរបស់លោកត្រូវបានដាក់ទាន់ពេលវេលាកំណត់ និងបានបំពេញលក្ខខណ្ឌស្តីពីការខិតខំយកចិត្តទុកដាក់យ៉ាងសមហេតុផលដូចមានចែងនៅក្នុងវិធាន ៨៧(៤) នៃ វិធានផ្ទៃក្នុង។ ផ្អែកលើមូលដ្ឋានទាំងនេះ នួន ជា បានស្នើសុំឲ្យអង្គជំនុំជម្រះកោះហៅសាក្សីចំនួន ១១១នាក់ ដែលបានផ្តល់ចម្លើយពាក់ព័ន្ធនឹងការកំណត់គោលដៅលើមន្ត្រីសាធារណរដ្ឋខ្មែរនៅក្នុងករណីដែលចម្លើយទាំងនេះត្រូវបានទទួលយក[62]។

16. សហព្រះរាជអាជ្ញាលើកឡើងថា សំណើសុំនេះត្រូវបានដាក់ពុំទាន់ពេលវេលាកំណត់ ហើយប្រឈមនឹងភាពគ្រប់គ្រាន់ និងភាពអាចទុកចិត្តបាននៃភស្តុតាង ដែលគួរតែលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលទើបមានលក្ខណៈសមស្របជាង[63]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រដំហររបស់សហ

[60] ប្រតិចារិក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៦២-៦៧ (ជាភាសាអង់គ្លេស)។ សំណើរបស់ នួន ជា សុំកោះហៅសាក្សី TCW-223 កថាខណ្ឌ ១៩-២១។

[61] សំណើរបស់ នួន ជា ស្នើសុំកោះហៅសាក្សី កថាខណ្ឌ ៩-២០។ ប្រតិចារិក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៥១-៥៤ ៥៩-៦០ (ជាភាសាអង់គ្លេស)។

[62] សំណើរបស់ នួន ជា ស្នើសុំកោះហៅសាក្សី កថាខណ្ឌ ២១-២៥។ ប្រតិចារិក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៥១-៥៤ ៥៩-៦០ (ជាភាសាអង់គ្លេស)។

[63] ប្រតិចារិក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៥៤-៥៨ (ជាភាសាអង់គ្លេស)។

ព្រះរាជអាជ្ញាដោយលើកឡើងថា សំណើសុំនេះគឺជាយុទ្ធវិធីដើម្បីពន្យារពេលវេលា និងថា ការស្នើសុំកោះហៅសាក្សីបន្ថែមទៀតជាការពុំចាំបាច់ឡើយ[64]។

## ៤. សម្អាងហេតុ

### ៤.១ ក្របខណ្ឌគតិយុត្តិ

17. កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹកដែលនឹងបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើកលែងតែមានអញ្ញត្រ-កម្មតិចតួចប៉ុណ្ណោះ គួរចាត់ទុកថា "មិនអាចអនុញ្ញាតឲ្យយកមកប្រើប្រាស់តាមច្បាប់ឡើយ" អនុលោមតាមវិធាន ៨៧(៣)(ឃ) នៃវិធានផ្ទៃក្នុង ហើយមិនអាចទទួលយកបានសម្រាប់គោលបំណងនេះទេ លើកលែងតែក្រុមមេធាវីការពារក្តីបានទទួលឱកាសដេញដោលអ្នកបានផ្តល់ចម្លើយទាំងនេះនៅក្នុងតុលាការ[65]។ ទោះបីជាយ៉ាងនេះក្តី ប្រសិនបើកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំងនេះមានការពាក់ព័ន្ធសម្រាប់បង្ហាញបញ្ហាផ្សេងៗក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់ និងបើមិនដូច្នោះទេ បានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង វាជាផលប្រយោជន៍នៃយុត្តិធម៌ ហើយជាការពន្លឿនកិច្ចដំណើរការនីតិវិធី ដែលភស្តុតាងបែបនេះត្រូវបានទទួលយក[66]។ ម្យ៉ាងវិញទៀត ការទទួលយកភស្តុតាងពុំអាចរារាំងទៅបានឡើយក្នុងករណីដែលសាក្សី

---

[64] ប្រតិចារឹក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៥៨-៥៩ (ជាភាសាអង់គ្លេស)។

[65] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ ទំព័រ ២១-២២។

[66] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ ទំព័រ ២៣-៣៣។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Milošević* សេចក្តីសម្រេចលើភាពអាចទទួលយកបាននៃភស្តុតាងរបស់អ្នកស៊ើបអង្កេតរបស់រដ្ឋអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលនៃ សាលាក្តី ICTY (IT-02-54-AR73.2) ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២ ("សេចក្តីសម្រេចលើកទីមួយលើករណី *Milošević*") កថាខណ្ឌ ១៨។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Milošević* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្គំលើភាពអាចទទួលយកបាននៃភស្តុតាងចម្បងក្នុងទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ អង្គជំនុំជម្រះតុលាការកំពូលនៃ សាលាក្តី ICTY (IT-02-54-AR73.4) ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៣ ("សេចក្តីសម្រេចលើកទីពីរលើករណី *Milošević*") កថាខណ្ឌ ១៤, ១៩។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Prlić និងជនផ្សេងទៀត* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចទទួលយកជាភស្តុតាងនូវប្រតិចារឹកសួរចម្លើយ *Jadranko Prlić* អង្គជំនុំជម្រះតុលាការកំពូលនៃ សាលាក្តី ICTY (IT-04-74-AR73.4) ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ *Prlic*") កថាខណ្ឌ ៥៥ ("ជាគោលការណ៍ គ្មានអ្វីអាចរារាំងការទទួលយកភស្តុតាងដែលពុំបានធ្វើតេស្តសាកល្បង ឬ មិនអាចធ្វើតេស្តសាកល្បងបានតាមរយៈការសួរដេញដោលសាក្សីរបស់ភាគីបដិបក្ខ") កថាខណ្ឌ ៥៧, ៦០-៦២ (ពុំបានរកឃើញមានកំហុសនៅក្នុងការទទួលយកភស្តុតាងស្តីពីសកម្មភាព និងអំពើរបស់ជនជាប់ចោទដើម្បីយកមកវាយតម្លៃនាពេលក្រោយដោយពិចារណាលើកំណត់ហេតុនៃការជំនុំជម្រះទាំងមូល។

បានទទួលមរណភាព, មិនអាចរកឃើញក្រោយពីបានខិតខំយកចិត្តទុកដាក់យ៉ាងសមហេតុផលរួចហើយ ឬពុំអាចរកបានដោយសារការគំរាមកំហែង ការបំភិតបំភ័យ ឬការជៀសវាងដោយពុំសមស្របណាមួយនោះ[67]។

18. កត្តានានាដែលគាំទ្រដល់ការទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំងនេះជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ រួមមានការពុំមានឱកាសពិតប្រាកដសម្រាប់តទល់គ្នាចំពោះមុខ (ដោយសារមរណភាព ការមិនមានលទ្ធភាពផ្នែកសុខភាពក្នុងការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ ឬពុំមានលទ្ធភាព ទោះបីជាបានខិតខំយកចិត្តទុកដាក់យ៉ាងត្រឹមត្រូវក៏ដោយ ក្នុងការស្វែងរកអ្នកផ្តល់ចម្លើយនោះ), លក្ខណៈបញ្ជាក់នៃភស្តុតាង និងករណីថាតើភស្តុតាងទាំងនោះបានបង្ហាញពីធាតុផ្សំអប្បបរមានៃឧក្រិដ្ឋកម្មអន្តរជាតិ (ដូចជា លក្ខណៈជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំរាលដាលនៃការវាយប្រហារ), មូលដ្ឋានឧក្រិដ្ឋកម្ម, ផលប៉ះពាល់លើជនរងគ្រោះ, សាវតារប្រវត្តិសាស្ត្រ ឬរចនាសម្ព័ន្ធរដ្ឋបាល[68]។ អង្គជំនុំជម្រះសូមកត់សម្គាល់ថា នៅក្នុងការអនុវត្តបទដ្ឋានដូចបានកំណត់នៅក្នុងសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ អង្គជំនុំជម្រះមិនបានអនុវត្តទាំងស្រុងនូវលក្ខខណ្ឌលម្អិត និងបច្ចេកទេសនៃវិធាន ៩២*ស្ទួន*, វិធាន ៩២*ស្ទួនពីរ* ឬ វិធាន ៩២*ស្ទួនបី* នៃតុលាការ ICTY នោះទេ[69]។

19. អង្គជំនុំជម្រះសូមបញ្ជាក់បំភ្លឺបន្ថែមទៀតថា បទដ្ឋានស្តីពី "អំពើ និងអាកប្បកិរិយា" ដែលបានប្រើនៅក្នុងសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយអនុវត្តតែចំពោះកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹក

---

[67] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ ទំព័រ ៣២-៣៣។

[68] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ ទំព័រ ១៧, ២៤-២៥, ៣២, ៣៤ ផ្នែកនៃសេចក្តីសម្រេច។

[69] សាលាក្តី ICTR សាលាក្តី ICTY សាលាក្តី STL តុលាការ ICC និងតុលាការ SCSL បានទទួលស្គាល់គោលការណ៍ទូទៅទាំងអស់គ្នាថា ភស្តុតាងរបស់សាក្សីមានតម្លៃជាភស្តុតាងតិចតួចប្រសិនបើពុំមានឱកាសឱ្យសួរដេញដោលតទល់គ្នា។ ក៏ប៉ុន្តែ បទប្បញ្ញត្តិលម្អិត និងបច្ចេកទេសនៅក្នុងវិធាន ៩២*ស្ទួន* វិធាន ៩២*ស្ទួនពីរ* វិធាន ៩២*ស្ទួនបី* នៃ ICTY ពុំឆ្លុះបញ្ចាំងដូចគ្នានៅក្នុងវិធានរបស់តុលាការអន្តរជាតិ (អន្តរជាតូបនីយកម្ម) ផ្សេងទៀតឡើយ។ អាស្រ័យហេតុនេះ បទប្បញ្ញត្តិទាំងនេះមិនអាចចាត់ទុកថាជាបទដ្ឋាននៃនីតិវិធីអន្តរជាតិដែលអនុវត្តទៅបានដោយស្វ័យប្រវត្តិនៅក្នុងបរិបទពិសេសនៃតុលាការអន្តរជាតិ (អន្តរជាតូបនីយកម្ម) ដទៃឡើយ (រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bemba* សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Jean-Pierre Bemba Gombo និងរដ្ឋអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទី III ស្តីពី "សេចក្តីសម្រេចលើការទទួលយកមកធ្វើជាភស្តុតាងនូវសម្ភារៈ/ឯកសារនៅក្នុងបញ្ជីភស្តុតាងរបស់រដ្ឋអាជ្ញា" អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC (ICC-01/05-01/08) ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១ កថាខណ្ឌ ៥៦)។ ហេតុដូច្នេះ អង្គជំនុំជម្រះច្រានចោលសេចក្តីសន្និដ្ឋានដោយផ្អែកលើលក្ខខណ្ឌលម្អិត និងបច្ចេកទេសនៅក្នុងវិធាននៃសាលាក្តី ICTY (ចម្លើយតបបឋមរបស់ នួន ជា កថាខណ្ឌ ២, ៥-១០។ ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៨-១៤។ សំណើសុំដែលត្រូវបានកែសម្រួលរបស់ ក.ស.ព កថាខណ្ឌ ១៧)។

ទាំងឡាយណាដែល "តាមលក្ខណៈរបស់វា" បង្ហាញអំពីអំពើ និងអាកប្បកិរិយាផ្ទាល់ខ្លួនរបស់ជនជាប់ចោទដូចបានចោទប្រកាន់តែប៉ុណ្ណោះ[70]។ ការបកស្រាយបទដ្ឋាននេះក្នុងគោលបំណងដកចេញកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកដែលបង្ហាញបញ្ហានានាក្រៅពីអំពើ និងអាកប្បកិរិយាផ្ទាល់ខ្លួនរបស់ជនជាប់ចោទដូចបានចោទប្រកាន់ ជាឧទាហរណ៍ ការបង្ហាញអំពីបញ្ហា "សំខាន់ៗ" នៅក្នុងករណីរបស់សហព្រះរាជអាជ្ញា, បញ្ហា "ដែលកំពុងមានការចាប់អារម្មណ៍" ដែលមានវិវាទ ឬអំពើ និងអាកប្ប-កិរិយានៃអង្គការ និងស្ថាប័នដែលជនជាប់ចោទជាសមាជិក បុគ្គលទាំងឡាយដែលជនជាប់ចោទជាប់ពាក់ព័ន្ធ ឬបុគ្គលិកក្រោមបង្គាប់ "ដែលនៅជិតបំផុត" នោះ ការបកស្រាយដូច្នេះ "នឹងប៉ះពាល់យ៉ាង មានប្រសិទ្ធភាពលើ [បទដ្ឋាននៃ] ការប្រើប្រាស់ជាក់ស្តែង"[71]។ ផ្ទុយមកវិញ ការជំទាស់ និងសារណាទាំងអស់ដោយផ្អែកលើមូលដ្ឋាននេះ រួមជាមួយនឹងលក្ខខណ្ឌដូចមានចែងនៅក្នុងសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ ត្រូវយកមកពិចារណានៅក្នុងពេលបញ្ចប់ការជំនុំជម្រះដើម្បីផ្តល់ទម្ងន់លើកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកណាដែលបានដាក់នៅចំពោះមុខអង្គជំនុំ-ជម្រះ[72]។ ដូចដែលអង្គជំនុំជម្រះបានសង្កត់ធ្ងន់កាលពីលើកមុនរួចហើយ ការដែលពុំមានសក្ខីកម្ម

---

[70] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ២១-២២, ៣០-៣១។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Galić សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំពាក់ព័ន្ធនឹងវិធាន ៩២*ស្ទួន*(គ) អង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តី ICTY (IT-98-29-AR73.2) ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០២ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ *Galić*") កថាខណ្ឌ ៩-១១, ១៥, ១៨។

[71] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ *Galić* កថាខណ្ឌ ៨-៩។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karemera និងជនផ្សេងទៀត* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចលើអង្គហេតុដែលបានទទួលយកដោយតុលាការ អង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តី ICTR (ICTR-98-44-AR73(គ)) ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៦ កថាខណ្ឌ ៥២។ *សូមមើលផងដែរ* ចម្លើយតបបឋមរបស់ នួន ជា លេខយោងជើងទំព័រ ២៩ *ដកស្រង់ នៅក្នុងចំណោមនោះ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Karadžić* អង្គជំនុំជម្រះសាលាដំបូងរបស់សាលាក្តី ICTY (IT-95-5/18 -T) សេចក្តីសម្រេចលើញត្តិលើកទីពីររបស់រដ្ឋអាជ្ញាស្នើសុំការទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកនៃភស្តុតាងជំនួសឲ្យសក្ខីកម្ម*ផ្ទាល់មាត់* អនុលោមតាមវិធាន ៩២*ស្ទួន* ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០ កថាខណ្ឌ ៤៤-៤៩។

[72] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ១៧, ២៥, ២៨, ៣២ និង ៣៤ ផ្នែកនៃសេចក្តីសម្រេច។ *សូមមើលផងដែរ* រឿងក្តី *Ndindabahizi ទល់នឹង រដ្ឋអាជ្ញា* អង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តី ICTR (ICTR-01-71-A) ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៧ កថាខណ្ឌ ៩៨។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Fofana និង Kondewa* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ SCSL (SCSL-04-14-A) ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៨ កថាខណ្ឌ ៤៤៨ ("ការពិភាក្សាវែកញែកលើភាពអាចទទួលយកបាននៃភស្តុតាងនៅក្នុងពេលជំនុំជម្រះជួយឲ្យអង្គជំនុំជម្រះអាចបញ្ជាក់បានច្បាស់លាស់អំពីបរិបទនៃភស្តុតាង និងដើម្បីវាយតម្លៃលើភាពពាក់ព័ន្ធ និងតម្លៃនៃភស្តុតាង")។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Martić សេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងរបស់សាក្សី Milan Babić អង្គជំនុំជម្រះតុលាការកំពូល

ផ្ទាល់មាត់ និងការដែលពុំមានឱកាសសម្រាប់តទល់ចំពោះមុខ គឺជាចំណុចពិចារណាពាក់ព័ន្ធនៅក្នុងការវាយតម្លៃអំពីតម្លៃ និងទម្ងន់ ប្រសិនបើមាន ចំពោះកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹកដែលត្រូវបានទទួលយកជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់នោះ[73]។

20. ក្រៅពីលក្ខខណ្ឌដូចបានកំណត់នៅក្នុងសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ ភស្តុតាងដែលបានស្នើឡើងទាំងអស់ត្រូវតែបំពេញ *ជាបឋម* នូវភាពពាក់ព័ន្ធ និងអាចទុកចិត្តបាន និងបើមិនដូច្នោះទេបានបំពេញលក្ខខណ្ឌនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ ភស្តុតាងដូចបានដកស្រង់ក្នុងកថាខណ្ឌនៃដីកាដំណោះស្រាយ ដូចបានដាក់បញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ទទួលបានការសន្មតថា មានភាពពាក់ព័ន្ធ និងភាពអាចទុកចិត្តបាន (រួមទាំងយថាភាព) ហើយកំណត់ហេតុស្តាប់ចម្លើយធ្វើឡើងនៅក្នុងពេលស៊ើបសួរ ទទួលបានការសន្មតថាអាចទុកចិត្តបាន[74]។ នៅក្នុងកិច្ចដំណើរការនិតីវិធីភាគីត្រូវបានបង្គាប់ឱ្យកំហិតត្រឹមភស្តុតាងដែលមានភាពពាក់ព័ន្ធដោយផ្ទាល់នឹងសំណុំរឿង ០០២/០១ ប៉ុណ្ណោះ[75]។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះបានទទួលយកភស្តុតាងពាក់ព័ន្ធនឹងគោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ និងទីតាំងឧក្រិដ្ឋកម្មនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១

---

នៃសាលាក្តី ICTY (IT-95-11-AR73.2) ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៦ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ *Martić*") កថាខណ្ឌ ១៥, ២៣។

[73] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ២៥, ២៧, ២៩។ *សូមមើលផងដែរ ករណី រដ្ឋអាជ្ញា ទល់នឹង* Aleksovski សេចក្តីសម្រេចលើបណ្តឹងសារទុក្ខរបស់រដ្ឋអាជ្ញាស្តីពីភាពអាចទទួលយកបាននៃភស្តុតាង សាលាឧទ្ធរណ៍ ICTY (IT-95-14/1) ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៤-១៥, ២៧។

[74] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ២៦។ សេចក្តីសម្រេចចុះខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៩ ក។ សេចក្តីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពមិនស៊ីសង្វាក់គ្នា នៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងខ្សែអាត់ជាសម្លេងនៃការស្តាប់ចម្លើយរបស់សាក្សី ក.ស.ច.ស ឯកសារលេខ E142/3 ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ៦-១៥។

[75] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ៣៤-៣៥។ អនុស្សារណៈចុះខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ៧។ *សូមមើលផងដែរ* ការឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃការប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E141 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២។ ការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មសាក្សី និងអ្នកជំនាញសម្រាប់ដើមឆ្នាំ ២០១៣ ឯកសារលេខ E236/4 ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ២។

ជាចម្បតា នៅពេលភស្តុតាងនេះទទួលបានក្នុងលក្ខណៈជាភស្តុតាងដែលពាក់ព័ន្ធដោយផ្ទាល់មួយផ្នែក និង/ឬ នៅពេលភស្តុតាងនេះពាក់ព័ន្ធនឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្មលើជនរងគ្រោះ[76]។

21. ពាក់ព័ន្ធនឹងភាពអាចទុកចិត្តបាន *ជាបឋម* នៃភស្តុតាងដែលបានស្នើឡើង អង្គជំនុំជម្រះបានកត់សម្គាល់ថា វិការៈតាមការចោទប្រកាន់ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយដែលត្រូវបានធ្វើឡើងនៅក្នុងពេលស៊ើបសួរ ត្រូវតែមានភាពជាក់លាក់ឱ្យបានគ្រប់គ្រាន់ និងត្រូវមានការពាក់ព័ន្ធច្បាស់លាស់ទៅនឹងការជំនុំជម្រះ[77]។ ការជំទាស់ពាក់ព័ន្ធនឹងកាលៈទេសៈនៃការធ្វើកំណត់ហេតុនេះ ដូចជាមូលហេតុចម្បងនៃប្រភពព័ត៌មាន ឬថាតើការស្តាប់ចម្លើយត្រូវបានថតខ្សែអាត់សម្លេងដែរឬអត់ វាហួសពីលក្ខណៈវិនិច្ឆ័យ *ជាបឋម* នៃភាពអាចទុកចិត្តបាន និងត្រូវយកមកពិចារណានៅក្នុងការកំណត់អំពីទម្ងន់នៅក្រោយពេលពិនិត្យ ពិចារណាសំណុំភស្តុតាងទាំងមូលនៅពេលបញ្ចប់ការជំនុំជម្រះ[78]។ ហេតុដូច្នេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា បញ្ហាភាពអាចទុកចិត្តបាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយដែលបានធ្វើដោយសហព្រះរាជអាជ្ញានៅក្នុងពេលស៊ើបអង្កេតបឋម និងប្រតិចារឹកសំណុំរឿង០០១ ក្នុងករណីដែលផលប្រយោជន៍របស់ភាគីខុសពីផលប្រយោជន៍របស់ភាគីនៅក្នុងសំណុំរឿង០០២ គឺជាកត្តាពាក់ព័ន្ធនឹងការវាយតម្លៃចុងក្រោយលើភស្តុតាង ពុំមែនពាក់ព័ន្ធនឹងភាពអាចទទួលយកបាននោះឡើយ។ ផ្ទុយពីសារណារបស់ នួន ជា តួនាទីរបស់សហព្រះរាជអាជ្ញានៅក្នុងការស៊ើបអង្កេតបឋម និងនៅក្នុងសំណុំរឿងផ្សេងទៀត ពុំមានផលប៉ះពាល់លើសមភាពរវាងគូភាគីក្តីឡើយ ដរាបណាភាគីទាំងអស់

---

[76] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ២៩។ សេចក្តីជូនដំណឹងអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើដែលនៅសេសសល់មុនសវនាការ (ឯកសារលេខ E20, E132, E134, E135, E124/8, E124/9, E124/10, E136 និង E139) និងការណែនាំបន្ថែមទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារលេខ E145 ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៣។ សេចក្តីសម្រេចលើសំណើសុំកោះហៅសារជាថ្មីដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 និងសុំឱ្យពិនិត្យឡើងវិញលើបែបបទពាក់ព័ន្ធនឹងសក្ខីកម្មស្តីពីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសំណើ និងចម្លើយតបនានាដែលពាក់ព័ន្ធ (ឯកសារលេខ E240, E240/1, E250, E250/1, E267, E267/1 និង E676/2) ឯកសារលេខ E267/3 ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ ("សេចក្តីថ្លែងលើសេចក្តីសម្រេចអំពីទុក្ខសោក") កថាខណ្ឌ ១៤-១៨។

[77] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ២៦។ *សូមមើលផងដែរ* សេចក្តីសម្រេចចុះខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៩-ច (ការជំទាស់ខ្វះលក្ខណៈជាក់លាក់គ្រប់គ្រាន់ត្រូវតែច្រានចោល)។

[78] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ២៦-២៩។ សេចក្តីសម្រេចចុះខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៩(ឃ) កថាខណ្ឌ ៨(ច) ១៣-១៤។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ *Prlić* កថាខណ្ឌ ៤៥, ៥២។ *សូមមើលផងដែរ* ការឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៧៧-៨២។

មានសមភាពផ្នែកនីតិវិធីនៅក្នុង*ការបង្ហាញ* រឿងក្តីរបស់ខ្លួន[79]។ លើសពីនេះទៀត នៅក្រោមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ការស៊ើបអង្កេតបឋមធ្វើឡើងដោយសហព្រះរាជអាជ្ញា ពុំដើរតួនាទីចំបងនៅក្នុងដំណាក់កាលមុនការជំនុំជម្រះឡើយ ផ្ទុយមកវិញ កិច្ចស៊ើបសួរដែលធ្វើឡើងជាចាំបាច់ក្រោយពេលស៊ើបអង្កេតបឋម មានសារៈសំខាន់ និងផ្តល់សិទ្ធិជាច្រើនជូនដល់ភាគីទាំងអស់[80]។ ជាចុងក្រោយ អង្គជំនុំជម្រះបានសម្រេចរួចហើយថា ការវិនិច្ឆ័យលើសំណុំរឿង០០១ ពុំមានផលប៉ះពាល់លើលទ្ធភាពរបស់ខ្លួនក្នុងការធ្វើឲ្យមានភាពពលម្អៀងនៅក្នុងសំណុំរឿង០០២ ឡើយ[81]។

22. ភស្តុតាងទាំងអស់ដែលពីមុនមិនមាននៅក្នុងសំណុំរឿង និង/ឬ មិនមាននៅក្នុងបញ្ជីរបស់ភាគី ស្របតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង គឺជាភស្តុតាងថ្មីដែលត្រូវគោរពតាមលក្ខខណ្ឌនៃភាពអាចទទួលយកបានដ៏តឹងរ៉ឹងនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ តាមរយៈសារណា ដោយមានសម្អាងហេតុ ភាគីត្រូវបង្ហាញថា ភស្តុតាងថ្មីទាំងនេះពុំអាចរកបាននៅមុនពេលបើកការជំនុំជម្រះ និង/ឬ មិនអាចរកឃើញ និងពុំត្រូវបានផ្តល់ឲ្យនៅពេលមុន ទោះបីជាបានខិតខំយកចិត្តទុកដាក់យ៉ាងត្រឹមត្រូវរួចហើយក៏ដោយ។ ភស្តុតាងថ្មីក៏ត្រូវតែអាចនាំដល់ការលាតត្រដាងការពិត និងត្រូវបំពេញលក្ខខណ្ឌនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងផងដែរ[82]។

---

[79] រឿងក្តី *Nahimana និងជនផ្សេងទៀត ទល់នឹង រដ្ឋអាជ្ញា* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តី ICTR (ICTR-99-52-A) ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ១៧៣។ រឿងក្តី *Jespers ទល់នឹង ប្រទេសប៊ែលហ្ស៊ិក* លេខ ៨៤៩៣ គណៈកម្មាការសិទ្ធិមនុស្សអឺរ៉ុប ២៧ D.R [១៩៨១] ៦១ ទំព័រ ៨៧ (ជាភាសាអង់គ្លេស)។

[80] នៅអំឡុងដំណាក់កាលស៊ើបសួរ ក្រុមមេធាវីការពារក្តី មិនខុសពីភាគីផ្សេងទៀត មានសិទ្ធិពិនិត្យសំណុំរឿង រួមទាំងសម្ភារៈ/ឯកសារដែលប្រមូលបាននៅក្នុងពេលស៊ើបអង្កេតបឋម។ នៅក្នុងករណីនេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាមានកាតព្វកិច្ចដោយយកចិត្តទុកដាក់បន្តទៀតដើម្បីលាតត្រដាងព័ត៌មានដោះបន្ទុកទាំងអស់ (វិធាន ៥៣ នៃវិធានផ្ទៃក្នុង)។ ម្យ៉ាងវិញទៀត ក្រុមមេធាវីការពារក្តីអាចស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរ ឬក៏ក្រុមមេធាវីការពារក្តីមានសិទ្ធិដាក់ពាក្យសុំដោយមានសម្អាងហេតុដើម្បីមោឃៈផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធី ដោយសារវិការៈ (វិធាន ៥៥(១០) និងវិធាន ៧៦ នៃវិធានផ្ទៃក្នុង)។ ជាចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាត្រូវបានហាមឃាត់មិនឲ្យធ្វើការស៊ើបអង្កេតដោយខ្លួនឯង នៅពេលដែលការស៊ើបអង្កេតបឋមបានបញ្ចប់ និងមុនពេលដែលជនសង្ស័យត្រូវបានដាក់ជាជនត្រូវចោទ ហើយធ្វើជាភាគីមួយនៃកិច្ចដំណើរការនីតិវិធី។

[81] សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងដិតចិត្តចំពោះលោកចៅក្រម និល ណុល, ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មុន្នី ឯកសារលេខ E55/4 ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ ១៧, ២០។ *សូមមើលផងដែរ* ការឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៨៣។

[82] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារលេខ E190 ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ១៦-២៣, ៣៨។

## ៤.២. ការវិភាគ

### ៤.២.១. កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកនៃសាក្សីដែលបានស្នើឡើងជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់

23. ទាំងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ទទួលស្គាល់ថា កំណត់ហេតុ និងប្រតិចារឹកដែលបានស្នើឡើង មានភស្តុតាងពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់ ប៉ុន្តែសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខសង្កត់ធ្ងន់ថា ពួកគេពុំបានព្យាយាមស្នើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយទាំងនេះសម្រាប់គោលបំណងបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទឡើយ[83]។ សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយរារាំងការទទួលយកកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹករបស់សាក្សីដែលអាចបង្ហាញអំពីអំពើ និងអាកប្បកិរិយាផ្ទាល់របស់ជនជាប់ចោទដូចបានចោទប្រកាន់។ ទោះបីជាយ៉ាងនេះក្តី គ្មានអ្វីអាចរារាំងការទទួលយកកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹកដែលអាចមានភស្តុតាងពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់ នៅពេលឯកសារទាំងនោះត្រូវបានស្នើឡើង និងនៅចុងក្រោយ ត្រូវបានយកមកធ្វើជាមូលដ្ឋានសម្រាប់គោលបំណងនានាក្រៅពីការបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទរួមទាំងភាពអាចទុកចិត្តបាននៃភស្តុតាងផ្សេងៗទៀត ដែលមាននៅក្នុងខ្សែអាត់ថតសម្លេង និងវីដេអូនោះទេ[84]។ ហេតុដូច្នេះ អង្គជំនុំជម្រះ បដិសេធសំណើរបស់ក្រុមមេធាវីការពារក្តីស្នើសុំដកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកដែលរួមមានភស្តុតាងពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ឬពាក់ព័ន្ធនឹងបញ្ហា "សំខាន់ៗ" ឬ "ដែលកំពុងចាប់អារម្មណ៍" ដោយសារតែការជំទាស់ទាំងនេះទាក់ទិននឹងកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹកដែលពាក់ព័ន្ធដល់ការបង្ហាញភស្តុតាងនៃបញ្ហានានាក្រៅពីអំពើ និងអាកប្បកិរិយាផ្ទាល់របស់ជនជាប់ចោទដូចបានចោទប្រកាន់។ ទោះបីជាយ៉ាងនេះក្តី សារណា និងការជំទាស់របស់ក្រុមមេធាវីការពារក្តីទាំងអស់នឹងត្រូវយកមកពិចារណានៅពេលកំណត់អំពីទម្ងន់ ប្រសិនបើមាន ចំពោះកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកនីមួយៗនៅក្នុងសាលក្រម។

---

[83] សំណើសុំដែលត្រូវបានកែសម្រួលរបស់ ក.ស.ព កថាខណ្ឌ ៤-៥, ៣២-៣៣។ សំណើសុំរបស់ ក.ស.ព ចុះខែ កក្កដា ឆ្នាំ ២០១២ កថាខណ្ឌ ២, ១៥-១៧។ ការឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ២១, ២៤, ២៨-៣០, ៦៤។ សំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៩-២៣, ២៨, ៣៤-៤១។ សំណើសុំដែលត្រូវបានកែសម្រួលរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៩។

[84] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ២០-២១, ៣០-៣១។ សេចក្តីសម្រេចលើកទីមួយលើករណី *Milošević* កថាខណ្ឌ ១៨, សេចក្តីសម្រេចលើកទីពីរលើករណី *Milošević* កថាខណ្ឌ ១៤, ១៩។

24. សហព្រះរាជអាជ្ញាស្នើសុំឱ្យកោសលុបព័ត៌មានពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទចេញពីកំណត់ហេតុស្តាប់ចម្លើយចំនួន ២២០ ដែលភាគច្រើនត្រូវបានស្នើសុំដាក់ដើម្បីបង្ហាញបញ្ហានានាក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់[85]។ ក្រុមមេធាវីការពារក្តីអះអាងថាខ្លួនពុំមានឱកាសគ្រប់គ្រាន់ពិនិត្យឡើងវិញលើការកោសលុប ដូចដែលបានស្នើសុំទាំងនេះទេ[86]។ អង្គជំនុំជម្រះកត់សម្គាល់ឃើញជាលើកដំបូងថា កំណត់ហេតុស្តាប់ចម្លើយដែលបានស្នើសុំឱ្យកោសលុបចំនួន ៦៧ ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយដែលត្រូវបានស្នើទាំងនេះ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងទម្រង់ដែលមិនមានការកោសលុបរួចហើយ ហើយកំណត់ហេតុស្តាប់ចម្លើយខ្លះទៀតត្រូវបានប្រើប្រាស់រួមជាមួយនឹងភស្តុតាងនានារបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនានាផងដែរ[87]។ ម្យ៉ាងវិញទៀត ក្នុងឱកាសមុននោះ ខៀវ សំផន បានស្នើសុំឱ្យទទួលយកយ៉ាងហោចណាស់កំណត់ហេតុស្តាប់ចម្លើយចំនួន ១១ ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយទាំងនេះ[88]។ ខៀវ សំផន និង/ឬ នួន ជា នាពេលមុន ក៏បានស្នើសុំឱ្យសាក្សីយ៉ាងហោចណាស់ចំនួន ២០ នាក់ដែលបានផ្តល់ចម្លើយ ហើយដែលចម្លើយទាំងនេះត្រូវបានស្នើសុំឱ្យកោសលុបនាពេលនេះនោះ ចូលខ្លួននៅចំពោះមុខតុលាការផងដែរ[89]។ ជាការឆ្លើយតបមកវិញ អង្គជំនុំជម្រះពិចារណាឃើញថា ផ្នែកខ្លះដែលត្រូវបានស្នើសុំឱ្យកោសលុបទាំងនោះអាចបង្ហាញភស្តុតាងដោះបន្ទុក ឬអាចបំពេញ កែតម្រូវ ឬបើមិនដូច្នោះទេ ប៉ះពាល់លើភាពអាចទុកចិត្តបាននៃកំណត់ហេតុស្តាប់ចម្លើយទាំងនេះទាំងមូល ឬនៃភស្តុតាងផ្សេងទៀតដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ[90]។ ហេតុដូច្នេះ អង្គជំនុំជម្រះបដិសេធមិនបង្គាប់ឱ្យកោសលុបតាមសំណើសុំរបស់សហព្រះរាជអាជ្ញាឡើយ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះនឹង

---

[85] សំណើសុំដែលត្រូវបានកែសម្រួលរបស់ ក.ស.ព កថាខណ្ឌ ៤-៥, ៣២-៣៣ (ការកោសលុបដូចដែលបានស្នើសុំត្រូវបានគូសបញ្ជាក់ជាអក្សរក្រហមនៅក្នុងប្រព័ន្ធ Zylab ដើម្បីឱ្យអង្គជំនុំជម្រះ និងភាគីងាយស្រួលពិនិត្យមើល)។

[86] ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៤៣។ ចម្លើយតបបន្ថែមរបស់ ខៀវ សំផន កថាខណ្ឌ ១០។

[87] E3/102; E3/1568; E3/1605; E3/1714; E3/185; E3/2073; E3/348; E3/351; E3/353; E3/354; E3/36; E3/360; E3/361; E3/362; E3/363; E3/364; E3/365; E3/376; E3/378; E3/382; E3/385; E3/387; E3/389; E3/390; E3/396; E3/3962; E3/397; E3/398; E3/399; E3/401; E3/412; E3/415; E3/416; E3/419; E3/420; E3/421; E3/422; E3/425; E3/426; E3/437; E3/44; E3/46; E3/462; E3/463; E3/465; E3/466; E3/467; E3/468; E3/469; E3/470; E3/471; E3/472; E3/473; E3/474; E3/506; E3/509; E3/521; E3/545; E3/546; E3/59; E3/68; E3/70; E3/71; E3/72; E3/79; E3/87; E3/96។

[88] D232/89; D94/10; D94/12 (E3/476); D201/7 (E3/385); D210/5 (E3/387); D125/164 (E3/365); D199/20 (E3/96); D223/14 (E3/412); D91/6; D94/6 (E3/473); IS 19.224។

[89] TCW-82; TCW-92; TCCP-21; TCW-231; TCW-295; TCW-301; TCW-410; TCW-425; TCW-326; TCW-748; TCCP-178; TCW-540; TCW-591; TCW-663; TCW-681; TCW-698; TCW-724; TCW-729; TCW-787; TCW-788។ ជាចុងក្រោយ សាក្សីទាំងនេះពុំត្រូវបានកោះហៅឱ្យមកចំពោះមុខអង្គជំនុំជម្រះឡើយ។

[90] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ *Galić* កថាខណ្ឌ ៤៦។

ពិចារណាលើការកោសលុបដូចបានស្នើសុំរួមជាមួយនឹងសារណា និងការជំទាស់ដទៃទៀត នៅពេលកំណត់អំពីទម្ងន់ ប្រសិនបើមាន លើកំណត់ហេតុស្តាប់ចម្លើយទាំងនេះនៅក្នុងសាលក្រម។

25. អង្គជំនុំជម្រះបានកំណត់យកកំណត់ហេតុស្តាប់ចម្លើយដូចដែលបានស្នើសុំចំនួន ២៤ (រួមទាំងកំណត់ហេតុស្តាប់ចម្លើយចំនួន ១៦ ដែលបានស្នើសុំឱ្យកោសលុប) ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសំណុំរឿង ០០២/០១ ព្រោះថាកំណត់ហេតុទាំងនេះបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់។ ហេតុដូច្នេះ អង្គជំនុំជម្រះច្រានចោលសំណើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយទាំងនេះ (ឧបសម្ព័ន្ធសម្ងាត់ ខ ផ្នែក ១)។

26. ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសម្រេចថា កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកចំនួន ១.១១៤ មានលក្ខណៈជាន់គ្នាទៅវិញទៅមក និង/ឬ ជាមួយនឹងភស្តុតាងផ្សេងទៀត រួមទាំងភស្តុតាងដែលជាសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលមាននៅក្នុងខ្សែអាត់សម្លេង និងវីដេអូ ហើយថាកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំងនេះ បានបំពេញ *ជាបឋម* អំពីភាពពាក់ព័ន្ធទៅនឹងភស្តុតាងនៃបញ្ហានានានៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់[91]។ កត្តាទាំងនេះមានទម្ងន់អាចគាំទ្រដល់ការទទួលយកកំណត់ហេតុ

---

[91] ដូច នួន ជា បានស្នើឡើង វាពុំមានលក្ខខណ្ឌតម្រូវថា ភស្តុតាងត្រួតគ្នាត្រូវបញ្ជាក់ ឬ បំពេញគ្នាជាមួយនឹងភស្តុតាងផ្សេងៗទៀតពាក់ព័ន្ធនឹងអង្គហេតុដូចគ្នាឡើយ។ ប៉ុន្តែ ភស្តុតាងត្រួតគ្នាត្រូវពាក់ព័ន្ធនឹងអង្គហេតុស្រដៀងគ្នា។ បើមិនដូច្នោះទេ ការយល់ផ្សេងពីនេះនឹងរារាំងដល់ផលប្រយោជន៍នៃយុត្តិធម៌ដែលកម្រិតអង្គជំនុំជម្រះ និងភាគីក្នុងការទទួលបានអង្គហេតុមួយបែប ឬ រឿងរ៉ាវមួយ ហើយដែលនឹងរារាំងការទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកផ្ទុយនឹងសក្ខីកម្មផ្ទាល់មាត់ (សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ២៤។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Mladić* សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញាស្នើសុំឱ្យទទួលយកភស្តុតាងអនុលោមតាមវិធាន ៩២*ក្វាទ* សាក្សី RM-159 អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តី ICTY (IT-09-92-T) ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ១០ (ដែលកត់សម្គាល់ថាករណីដែលថាកំណត់ហេតុស្តាប់ចម្លើយនេះផ្ទុយនឹងភស្តុតាងផ្សេងនៅក្នុងកំណត់ហេតុនៃការជំនុំជម្រះ "គ្មានមូលដ្ឋានសម្រាប់ការច្រានចោលលើការទទួលយកឡើយ")។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Nizeyimana* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចមិនទទួលយកចម្លើយរបស់ Marcel Gatsinzi មកធ្វើជាភស្តុតាង អនុលោមតាមវិធាន ៩២*ក្វាទ* អង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តី ICTR (ICTR-00-55C-AR73.2) ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០១១ កថាខណ្ឌ ១៣)។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះច្រានចោលការជំទាស់របស់ក្រុមមេធាវីការពារក្តីដោយសារហេតុផលនេះ (ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ២៤-៣០។ សំណើសុំរបស់ នួន ជា ពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ កថាខណ្ឌ ៨, ៣៦។ ការឆ្លើយតបរបស់ នួន ជា ពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ កថាខណ្ឌ ៣-៦, ៨)។ ចំពោះភាពពាក់ព័ន្ធ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយនានាមានភាពពាក់ព័ន្ធដោយផ្ទាល់ទៅនឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្មមកលើជនរងគ្រោះបើទោះជាកំណត់ហេតុស្តាប់ចម្លើយទាំងនេះមានភាពពាក់ព័ន្ធទៅនឹងបញ្ហានានានៅក្រៅ

ស្តាប់ចម្លើយ និងប្រតិចារិកទាំងនេះ។ អង្គជំនុំជម្រះក៏បានរំលឹកថា កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិកដូចបានដកស្រង់នៅក្នុងលេខយោងជើងទំព័រនៃដីកាដំណោះស្រាយដែលបានបញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ បានទទួលការសន្មតពីភាពអាចទុកចិត្តបាន និងភាពពាក់ព័ន្ធរួចហើយ ហើយកំណត់ហេតុស្តាប់ចម្លើយធ្វើឡើងនៅក្នុងអំឡុងកិច្ចស៊ើបសួរ ក៏ទទួលបានការសន្មតនៃភាពអាចទុកចិត្តបានផងដែរ។ ម្យ៉ាងវិញទៀត ការជំទាស់របស់ក្រុមមេធាវីការពារក្តីទាំងអស់ចំពោះភាពអាចទុកចិត្តបាននៃកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិក គឺពាក់ព័ន្ធនឹងកាលៈទេសៈដែលកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិកត្រូវបានរៀបចំឡើង រួមទាំងថាតើការស្តាប់ចម្លើយទាំងនេះត្រូវបានថតខ្សែអាត់សម្លេងដែរឬទេ ឬក៏ការស្តាប់ចម្លើយទាំងនេះសំដៅលើហេតុផលដូចដែលបានចោទប្រកាន់នៅពីក្រោយការស្តាប់ចម្លើយដែលត្រូវបានធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់សហព្រះរាជអាជ្ញា បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គភាពដទៃៗនៅក្រៅ អ.វ.ត.ក[92]។ ការជំទាស់ទាំងនេះហួសពីភាពអាចជឿទុកចិត្តបាន*ជាបឋម* នៃកំណត់ហេតុស្តាប់ចម្លើយដែលបានស្នើសុំ និងត្រូវយកមកពិចារណានៅពេលកំណត់អំពីទម្ងន់ ប្រសិនបើមាននៅក្នុងសាលក្រម មិនមែននៅក្នុងដំណាក់កាលទទួលយកឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិកទាំង ១.១១៤ របស់សាក្សីជំនួសឱ្យការស្តាប់សក្ខីកម្មផ្ទាល់មាត់ (ឧបសម្ព័ន្ធសម្ងាត់ ក ផ្នែក ១)[93]។

27. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិកនានារបស់សាក្សី ត្រូវបានផ្តល់លេខសម្គាល់ E3 នៅក្នុងសេចក្តីសម្រេចលើឯកសារនាពេលមុន ឬក៏នៅក្រោយពេលបង្ហាញឯកសារទាំងនេះនៅក្នុងតុលាការ ប៉ុន្តែមិនបានដាក់បញ្ចូលនៅក្នុងសំណើសុំកែប្រែរបស់ ក.ស.ព ឬដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ[94]។ អង្គជំនុំជម្រះក៏បានកំណត់រួចរាល់ហើយថា កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិកទាំងនេះមានភាពពាក់ព័ន្ធ និងអាចទុកចិត្តបាន*ជាបឋម* ស្របតាមវិធាន ៨៧(៣)

---

វិសាលភាពនៃសំណុំរឿង ០០២/០១ ក៏ដោយ។ តាមការអនុវត្ត អង្គជំនុំជម្រះបានទទួលយកភស្តុតាងដែលប៉ះពាល់លើជនរងគ្រោះ ទោះបីជាភស្តុតាងទាំងនេះស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ ក៏ដោយ (សេចក្តីសម្រេចលើសក្ខីកម្មស្តីពីទុក្ខសោក)។

[92] ចម្លើយតបបឋមរបស់ នួន ជា កថាខណ្ឌ ៤០-៤៦។ ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៤០-៤២, ៤៥-៥២។ ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៣៤-៤៥។

[93] ដរាបណាកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិកទាំងនេះត្រូវបានផ្តល់លេខ E3 រួចរាល់អស់ហើយនៅក្នុងសេចក្តីសម្រេចលើឯកសារនាពេលមុនៗ និង/ឬនៅក្នុងពេលស្តាប់សក្ខីកម្មរបស់សាក្សីនានា នៅពេលនោះអង្គជំនុំជម្រះបញ្ជាក់ទទួលស្គាល់លេខ E3 នេះ ដោយបានរកឃើញថា កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិកទាំងនេះបានបំពេញបទដ្ឋានជាធរមានអនុវត្តចំពោះកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិក។

[94] *សូមមើល ឧទាហរណ៍* សេចក្តីសម្រេចលើឯកសារក្របខណ្ឌ ឧបសម្ព័ន្ធ A ទំព័រ ១៩-៣៧, ៤១-៤៨។

នៃវិធានផ្ទៃក្នុង។ ដោយហេតុថា កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំងនេះត្រូវបានទទួលយកដើម្បីបង្ហាញបញ្ហានានាក្រៅពីអំពើ និងអាកប្បកិរិយាផ្ទាល់របស់ជនជាប់ចោទដូចបានចោទប្រកាន់ អង្គជំនុំជម្រះសូមបញ្ជាក់នាពេលនេះថា កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំងនេះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះយ៉ាងពិតប្រាកដ ហើយពិតជាបានបំពេញលក្ខខណ្ឌនៃភាពអាចទទួលយកបានដែលអនុវត្តចំពោះកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ។

28. ចំណុចចុងក្រោយ អង្គជំនុំជម្រះសម្រេចថា ដោយហេតុថាកំណត់ហេតុស្តាប់ចម្លើយ ឬ ប្រតិចារឹករបស់សាក្សីរួមមានភស្តុតាងពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់ អង្គជំនុំជម្រះនឹងមិនផ្អែកលើព័ត៌មានទាំងនេះដើម្បីបង្ហាញពីអំពើ ឬអាកប្បកិរិយាដោយផ្ទាល់របស់ជនជាប់ចោទដូចបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០១ ឡើយ[95]។

**៤.២.២. កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដែលបានទទួលមរណភាព**

29. សហព្រះរាជអាជ្ញាស្នើសុំដាក់កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ដែលបានទទួលមរណភាពនៅចំពោះមុខអង្គជំនុំជម្រះដើម្បីបង្ហាញអំពីបញ្ហានានានៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ រួមទាំងអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់[96]។ ដោយផ្អែកលើសារណារបស់ភាគី និងក្រោយពីពិនិត្យឡើងវិញលើឯកសារពាក់ព័ន្ធ អង្គជំនុំជម្រះជឿជាក់ថា សាក្សីដែលបានផ្តល់ចម្លើយដូចបានកំណត់នៅក្នុងឧបសម្ព័ន្ធសម្ងាត់ ក ផ្នែក ២ បានទទួលមរណភាពហើយ[97]។ អង្គជំនុំជម្រះសូមរំលឹកឡើងវិញថា កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព អាចទទួលយកបាន រួមទាំងសម្រាប់គោលបំណងក្នុងការបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់ ប្រសិនបើកំណត់ហេតុទាំងនោះមានការពាក់ព័ន្ធ និងអាចទុកចិត្តបាន*ជាបឋម* និងប្រសិនបើមិនដូច្នោះទេ ចម្លើយទាំងនេះបានបំពេញលក្ខខណ្ឌនៃវិធាន

---

[95] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ១៩, ២១។

[96] សំណើសុំដែលត្រូវបានកែសម្រួលរបស់ ក.ស.ព កថាខណ្ឌ ៣១។ ឧបសម្ព័ន្ធដែលត្រូវបានកែសម្រួលលេខ ១២ ផ្នែក ឃ។

[97] អង្គជំនុំជម្រះមានសិទ្ធិសន្និដ្ឋានដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានតែឯកឯងបានថា សាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណីបានទទួលមរណភាព (សេចក្តីសម្រេចលើលើបណ្តឹងសាទុក្ខ *Galić* កថាខណ្ឌ ៣៣។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ *Martić* កថាខណ្ឌ ២៨)។ ចាប់តាំងពីពេលដាក់សំណើសុំកែសម្រួលរបស់ ក.ស.ព រួចមក អង្គជំនុំជម្រះបានទទួលការជូនដំណឹងថា សាក្សីម្នាក់ទៀតដែលកំណត់ហេតុស្តាប់ចម្លើយត្រូវបានស្នើសុំដាក់ជំនួសសក្ខីកម្មផ្ទាល់មាត់បានទទួលមរណភាព (*សូមមើល* លិខិតបញ្ជាក់មរណភាពរបស់ TCW-699 ឯកសារលេខ E292/1/3.1 ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៣)។

៨៧(៣) នៃវិធានផ្ទៃក្នុង[98]។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះកត់សម្គាល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព ទោះបីជាអាចទទួលយកបានដើម្បីបង្ហាញអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់ក៏ដោយ អាចមានតម្លៃជាភស្តុតាងតិចតួច ហើយការសម្រេចឱ្យជាប់ពិរុទ្ធភាពមិនអាចផ្អែកទាំងស្រុង ឬជាសំខាន់លើកំណត់ហេតុស្តាប់ចម្លើយទាំងនេះឡើយ។

30. បន្ទាប់ពីបានពិនិត្យមើលទៅលើកំណត់ហេតុស្តាប់ចម្លើយដែលបានស្នើឡើងរួចមក អង្គជំនុំជម្រះយល់ឃើញថា ចម្លើយទាំងដប់របស់សាក្សីដែលបានស្លាប់ រួមទាំងចម្លើយដែលត្រូវបានដកស្រង់នៅក្នុងជើងទំព័រនៃដីកាដំណោះស្រាយ ដែលទទួលបានសច្ចធារណ៍នៃភាពពាក់ព័ន្ធ គឺមានការពាក់ព័ន្ធ *ជាបឋម* នៅក្នុងសំណុំរឿង ០០២/០១។ បន្ថែមពីលើនេះ ការជំទាស់ទាំងអស់របស់មេធាវីការពារក្តីចំពោះភាពអាចជឿជាក់បាននៃកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិកដែលបានស្នើឡើង មិនស្ថិតនៅក្នុងភាពអាចជឿជាក់បាន *ជាបឋម* នៃឯកសារដែលបានស្នើឡើងនេះទេ[99]។ ទោះបីជាយ៉ាងណាក៏ដោយ ការជំទាស់ទាំងអស់នេះនឹងត្រូវយកទៅពិចារណានៅក្នុងពេលកំណត់អំពីតម្លៃទៅលើភស្តុតាងទាំងនេះនៅក្នុងសាលក្រម។ លើសពីនេះ អង្គជំនុំជម្រះយល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយទាំងអស់នេះ រួមទាំងកំណត់ហេតុស្តាប់ចម្លើយដែលបានដាក់បញ្ចូលទៅក្នុងជើងទំព័រពាក់ព័ន្ធនៃដីកាដំណោះស្រាយ និង/ឬទទួលបានពីកិច្ចស៊ើបសួរតាមផ្លូវតុលាការ ដែលទទួលបានសច្ចធារណ៍នៃភាពអាចជឿជាក់បាន គឺមានលក្ខណៈអាចទុកចិត្តបាន *ជាបឋម*។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេចទទួលយកកំណត់ហេតុស្តាប់ចម្លើយទាំងដប់ ដែលបានផ្តល់ដោយសាក្សីដែលបានទទួលមរណភាពទៅហើយ (ឧបសម្ព័ន្ធសម្ងាត់ ក, ផ្នែកទី ២)[100]។

---

[98] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ៣២-៣៣។

[99] មេធាវីការពារក្តីបានជំទាស់លើភាពអាចជឿជាក់បាននៃកំណត់ហេតុស្តាប់ចម្លើយដែលមិនមានភ្ជាប់ជាមួយនូវខ្សែអាត់សម្លេងនៅក្នុងសំណុំរឿង ហើយនិងចម្លើយដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ព ក៏ដូចជាដោយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងស្ថាប័នដទៃទៀតដែលមិនស្ថិតក្រោម អ.វ.ត.ក (ចម្លើយតបបឋមរបស់ នួន ជា កថាខណ្ឌ ៤០-៤៦, ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៤០-៤២, ៤៥-៥២, ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៣៤-៤៥)។

[100] ដោយសារតែកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិកទាំងអស់នេះត្រូវបានផ្តល់នូវលេខ E3 នៅក្នុងសេចក្តីសម្រេចស្តីពីឯកសារកាលពីពេលមុន និង/ឬ នៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់សាក្សីនានានោះ អង្គជំនុំជម្រះសូមអះអាងចំពោះឯកសារ E3 ទាំងនោះ ដោយយល់ឃើញថាកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិកទាំងអស់នេះបំពេញបានតាមបទដ្ឋានជាធរមានចំពោះកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ និងប្រតិចារិក។

### ៤.២.៣. ឯកសារដទៃទៀត

31. អង្គជំនុំជម្រះសាលាដំបូងបានកំណត់អត្តសញ្ញាណឯកសារចំនួន ២៤ នៅក្នុងឧបសម្ព័ន្ធ ១២ ដែលត្រូវបានកែប្រែ ថាមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ឯកសារទាំងនោះរួមមានសុន្ទរកថា និងកិច្ចសម្ភាសន៍ជាមួយ ប៉ុល ពត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, សុន្ទរកថារបស់អតីតមន្ត្រីមួយរូបនៃអង្គការ UNICEF ប្រតិចារឹកនៃឯកសារប្រវត្តិសាស្ត្រ និងរបាយការណ៍ពាក់ព័ន្ធនឹងចេតនាក្នុងការស្វែងរកបុគ្គលដែលបាត់ខ្លួន (ឧបសម្ព័ន្ធសម្ងាត់ ក, ផ្នែកទី៣) [101]។ បទដ្ឋាននៃភាពអាចទទួលយកបាន ដែលមានលក្ខណៈរឹតបន្តឹងខ្ពស់ ដូចមានចែងក្នុងសេចក្តីសម្រេចស្តីពីកំណត់ហេតុស្តាប់ចម្លើយនេះ អាចអនុវត្តបានតែចំពោះកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹក ហើយបទដ្ឋាននេះ មិនប៉ះពាល់ដល់ភាពអាចទទួលយកបាននៃភស្តុតាងដទៃទៀតនោះទេ។ ហេតុដូច្នេះ ឯកសារទាំង ២៤ នេះ គ្រាន់តែចាំបាច់ត្រូវមានភាពអាចជឿជាក់បាន និងភាពពាក់ព័ន្ធ *ជាបឋម* អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងប៉ុណ្ណោះ។

32. អង្គជំនុំជម្រះយល់ឃើញថា ឯកសារទាំងអស់នេះ រួមទាំងឯកសារដែលបានដាក់បញ្ចូលទៅក្នុងជើងទំព័រនៃដីកាដំណោះស្រាយ មានភាពពាក់ព័ន្ធ*ជាបឋម* ចំពោះសំណុំរឿង ០០២/០១។ បន្ថែមពីលើនេះ ការជំទាស់របស់មេធាវីការពារក្តីទាំងអស់ ចំពោះភាពអាចជឿជាក់បាននៃឯកសារដែលបានស្នើឡើងទាំងនេះ ពាក់ព័ន្ធទៅនឹងបរិបទដែលឯកសារនោះត្រូវបានធ្វើឡើង ដូចជាមូលហេតុពិតប្រាកដអំពី ប្រភព និង/ឬ គោលបំណងនៅពីក្រោយបណ្តាឯកសារដែលមានប្រភពមកពីខាងក្រៅ អ.វ.ត.ក ជាដើម[102]។ ការជំទាស់ទាំងអស់នេះមិនមែនអំពីភាពអាចជឿជាក់បាន*ជាបឋម* នៃភស្តុតាងដែលបានស្នើឡើង ដូច្នេះ ការជំទាស់ទាំងអស់នេះត្រូវយកទៅពិចារណានៅក្នុងការកំណត់តម្លៃ ប្រសិនបើមាននៅក្នុងសាលក្រម។ បន្ទាប់ពីបានពិនិត្យលើឯកសារដែលបានស្នើឡើងទាំងនេះ អង្គជំនុំជម្រះយល់ឃើញថា ឯកសារទាំងអស់នេះអាចជឿជាក់បាន*ជាបឋម*។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចទទួលយកឯកសារទាំងនេះ (ឧបសម្ព័ន្ធសម្ងាត់ ក, ផ្នែកទី ៣)។

---

[101] ភស្តុតាងនេះត្រូវបានរៀបចំឡើងក្នុងលក្ខណៈធម្មតា ដោយបុគ្គលដែលមានចំណាប់អារម្មណ៍ ផ្សេងពីការផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ ដូច្នេះភស្តុតាងទាំងនេះមិនអាចចាត់ទុកថាជាចម្លើយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីទេ (ប្រតិចារឹក ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១២ ទំព័រ ៧៦-៧៧ (ជាភាសាអង់គ្លេស), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ *Galic* កថាខណ្ឌ ២៨-៣១ សូមមើលផងដែរ ការឆ្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៥៧)។

[102] ចម្លើយតបបឋមរបស់ នួន ជា កថាខណ្ឌ ៤០-៤៦, ចម្លើយតប នួន ជា កថាខណ្ឌ ៤០-៤២, ៤៥-៥២ ចម្លើយតប ខៀវ សំផន កថាខណ្ឌ ៣៤-៤៥។

00944904



### ៤.២.៤. ភស្តុតាងនៃអង្គហេតុដែលបានស្នើឡើង ស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១

33. សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ បានស្នើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹក ដែលពួកគេបានទទួលស្គាល់ថាហួសពីវិសាលភាពនៃសំណុំរឿង ០០២/០១ (បើទោះបីជាមានការអះអាងថាឯកសារទាំងនេះសំខាន់សម្រាប់បង្ហាញពីគោលនយោបាយទូទៅ ព្រមទាំងបរិបទ និងធាតុផ្សំជាអប្បបរមានានា)[103]។ នួន ជា និងខៀវ សំផន បានជំទាស់[104]។

34. អង្គជំនុំជម្រះយល់ថា កំណត់ហេតុស្តាប់ចម្លើយ ព្រមទាំងប្រតិចារឹក និងឯកសារដទៃទៀតសរុបចំនួន ១២២ នេះ ពាក់ព័ន្ធនឹងការចោទប្រកាន់ផ្នែកអង្គហេតុ ដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១។ កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំងនេះ មិនត្រូវបានដាក់បញ្ចូលទៅក្នុងជើងទំព័រ ដែលពាក់ព័ន្ធនៃដីកាដំណោះស្រាយ ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ នោះទេ ដូច្នេះមិនមានសច្ចធារណ៍នៃភាពពាក់ព័ន្ធនោះទេ។ លើសពីនេះទៀត អង្គជំនុំជម្រះពិចារណាថា កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំងនេះ មិនមានសារៈសំខាន់សម្រាប់ឱ្យសហព្រះរាជអាជ្ញារួចផុតពីបន្ទុកក្នុងការបង្ហាញភស្តុតាងរបស់ខ្លួន អំពីគោលនយោបាយសហឧក្រិដ្ឋកម្មរួម ដែលត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ ឬក៏អំពីលក្ខណៈនៃការវាយប្រហារជាប្រព័ន្ធ និងក្នុងទ្រង់ទ្រាយធំទៅលើប្រជាជនស៊ីវិលឡើយ។ តាមពិត កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកចំនួន ១,៣៩៩ ដែលត្រូវបានទទួលយកដោយសេចក្តីសម្រេចនេះ (ឧបសម្ព័ន្ធសម្ងាត់ ក) ក្រៅពីពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសំណុំរឿង ០០២/០១ ហើយនោះ កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំងនេះ មានចំណុចគំរូជារួម និងជាតំណាងនៃទីតាំងឧក្រិដ្ឋកម្មទាំងអស់ ព្រមទាំងគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ ដូចមានកំណត់នៅក្នុងដីកាដំណោះស្រាយសំណុំរឿង ០០២។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេចបដិសេធសំណើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំង ១២២ ដែលមានលក្ខណៈច្រំដែល និងមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ (ឧបសម្ព័ន្ធសម្ងាត់ ខ ផ្នែកទី ២)។

### ៤.២.៥. ភស្តុតាងថ្មី (វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង)

[103] សំណើខែ កក្កដា ឆ្នាំ ២០១២ របស់ ក.ស.ព កថាខណ្ឌ ៨-១២, ១៨-១៩, ២០-២៨, ៣០-៣៤, សំណើដែលត្រូវបានកែសម្រួលរបស់ ក.ស.ព កថាខណ្ឌ ៣, ២៤, ២៨-៣០, ៤២, សំណើដែលត្រូវបានកែសម្រួលរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៩។

[104] ចម្លើយតប ខៀវ សំផន កថាខណ្ឌ ៣៤-៤៥, ចម្លើយតបបឋម នួន ជា កថាខណ្ឌ ៣៧-៣៩, ចម្លើយតប នួន ជា កថាខណ្ឌ១៥, ១៧-២៣។

### ៤.២.៥.១. សំណើកែប្រែថ្មីរបស់សហព្រះរាជអាជ្ញា

35. សហព្រះរាជអាជ្ញាបានស្នើសុំដាក់កំណត់ហេតុស្តាប់ចម្លើយចំនួន ១៥ ដែលទទួលបានដោយរួមទាំងពីការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ហើយមិនមាននៅក្នុងបញ្ជីនៃភស្តុតាងរបស់ខ្លួន យោងតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុងឡើយ[105]។ កំណត់ហេតុស្តាប់ចម្លើយទាំងនេះត្រូវបានធ្វើឡើងនៅចន្លោះខែកក្កដា ឆ្នាំ ២០១០ រហូតដល់ខែ កញ្ញា ឆ្នាំ ២០១១ ហើយត្រូវបានបង្ហាញជូនភាគីនានានៃសំណុំរឿង ០០២ នៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២[106]។ ទោះបីយ៉ាងណាក៏ដោយ កំណត់ហេតុទាំងនេះត្រូវបានស្នើសុំនៅក្នុងសំណើកែប្រែថ្មីរបស់សហព្រះរាជអាជ្ញា កាលពីថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ ត្រឹមតែឱ្យមានការទទួលយកតែប៉ុណ្ណោះ។ អង្គជំនុំជម្រះសូមរំឭកថា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ភាគីត្រូវតែបង្ហាញថាខ្លួនបានយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងការស្វែងរក និងបង្ហាញភស្តុតាងដែលមិនអាចរកបានមុនពេលបើកការជំនុំជម្រះ និង/ឬមិនមាននៅក្នុងបញ្ជីស្របតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាមិនបានដាក់សំណើដោយមានសម្អាងហេតុអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថា សហព្រះ-រាជអាជ្ញាមិនបានបង្ហាញពីការយកចិត្តទុកដាក់គ្រប់គ្រាន់ ក្នុងការស្វែងរក និង/ឬបង្ហាញភស្តុតាងថ្មីដែលបានស្នើឡើងក្នុងគោលបំណងចោទប្រកាន់ ក្នុងរយៈពេលជាងពីរឆ្នាំ ក្រោយពេលដែលសហព្រះ-រាជអាជ្ញាបានទទួល និងក្នុងរយៈពេលជាងមួយឆ្នាំ ក្រោយពេលដែលឯកសារទាំងនេះត្រូវបានបង្ហាញដល់អង្គជំនុំជម្រះ និងភាគីនានាឡើយ។

36. ទោះជាយ៉ាងណាក៏ដោយ ដោយពិចារណាថា កំណត់ហេតុស្តាប់ចម្លើយថ្មីចំនួនបួនក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយថ្មីទាំងអស់នេះ ត្រូវបានផ្តល់ឱ្យដោយសាក្សីដែលបានមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ដែលក្នុងពេលផ្តល់សក្ខីកម្មនោះ មេធាវីការពារក្តីមានឱកាសសួរដេញដោលទៅលើសាក្សី ទើបអង្គជំនុំជម្រះសម្រេចថា ដើម្បីជាប្រយោជន៍យុត្តិធម៌ ចម្លើយទាំងនេះនឹងត្រូវទទួលការវាយតម្លៃរួម ជាមួយសក្ខីកម្មដែលសាក្សីទាំងនោះបានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចដាក់កំណត់ហេតុស្តាប់ចម្លើយទាំងបួននេះទៅក្នុងសំណុំរឿង និងដាក់កំណត់ហេតុទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះ (ឧបសម្ព័ន្ធសម្ងាត់ ក ផ្នែកទី ៤)។ អង្គជំនុំជម្រះបដិសេធមិនទទួល

---

[105] សំណើដែលត្រូវបានកែសម្រួលរបស់ ក.ស.ព កថាខណ្ឌ ២, ឧបសម្ព័ន្ធ ១២ កែប្រែថ្មី។

[106] ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះអង្គជំនុំជម្រះសាលាដំបូង អំពីចម្លើយសាក្សីសំណុំរឿង ០០២ នៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលអនុលោមតាមអនុស្សរណៈ E127/4 របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២, E127/5។

យកចម្លើយសាក្សីថ្មីៗផ្សេងទៀតចូលទៅក្នុងសំណុំរឿងទេ ហើយសម្រេចបដិសេធទៅលើសំណើសុំដាក់បញ្ចូលឯកសារទាំងអស់នេះ (ឧបសម្ព័ន្ធសម្ងាត់ ខ ផ្នែកទី ៣)។

### ៤.២.៥.២. "សំណើរបស់ នួន ជា សុំឱ្យកោះហៅសាក្សី ពាក់ព័ន្ធទៅនឹងការចោទប្រកាន់អំពីគោលនយោបាយនៃការកំណត់មុខសញ្ញាមន្ត្រីរបបសាធារណរដ្ឋខ្មែរ"

37. ក្នុងករណីដែលកំណត់ហេតុស្តាប់ចម្លើយមួយចំនួនពាក់ព័ន្ធនឹងការកំណត់មុខសញ្ញាមន្ត្រីសាធារណរដ្ឋខ្មែរត្រូវបានទទួលយក ជំនួសការផ្តល់សក្ខីកម្មដោយផ្ទាល់នោះ នួន ជា ស្នើដល់អង្គជំនុំជម្រះឱ្យកោះហៅសាក្សីចំនួន ១១១ នាក់ដែលបានផ្តល់កំណត់ហេតុស្តាប់ចម្លើយទាំងនេះ[107]។ អង្គជំនុំជម្រះសូមកត់សម្គាល់ថា សាក្សីមួយរូបក្នុងចំណោមសាក្សីទាំងអស់នេះត្រូវបានស្នើកាលពីពេលមុនដោយ នួន ជា ហើយ សាក្សីប្រាំពីររូបទៀតត្រូវបានស្នើកាលពីពេលមុនដោយសហព្រះរាជអាជ្ញា[108]។ អង្គជំនុំជម្រះបានសម្រេចរួចហើយថា តើសាក្សីរូបណាខ្លះ ដែលនឹងមិនត្រូវកោះហៅមកបង្ហាញខ្លួននៅក្នុងសវនាការនោះ[109]។ ហេតុដូច្នេះ ពាក់ព័ន្ធទៅនឹងសាក្សីទាំងប្រាំបីរូបនេះ មេធាវីការពារក្តីពិតជាបានស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការពិចារណាឡើងវិញនូវសេចក្តីសម្រេចពីមុនរបស់អង្គជំនុំជម្រះក្នុងការមិនកោះហៅសាក្សីទាំងអស់នេះ។ មិនមានការចោទប្រកាន់អំពីអង្គហេតុថ្មីនោះទេ។ ដូច្នេះ អង្គជំនុំជម្រះ

---

[107] សំណើសុំកោះហៅរបស់ នួន ជា កថាខណ្ឌ ៩ -២០, ប្រតិចារឹក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៥១-៥៤ និង ៥៩-៦០ (ជាភាសាអង់គ្លេស)។ នួន ជា កំណត់អត្តសញ្ញាណសាក្សីដែលគាត់ស្នើសុំឱ្យកោះហៅ ព្រមទាំងចម្លើយពាក់ព័ន្ធដែលមានក្នុងឧបសម្ព័ន្ធ ក នៃសំណើរបស់គាត់ (ឧបសម្ព័ន្ធ ក សាក្សីដែលដកស្រង់ដោយ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីគោលនយោបាយកំណត់មុខសញ្ញាចំពោះមន្ត្រី និងទាហានលន់ នល់ ដែលត្រូវសម្លាប់ E291/2.1)។

[108] នួន ជា កាលពីមុនបានស្នើសុំសាក្សី TCW-38។ សហព្រះរាជអាជ្ញាកាលពីមុនបានស្នើសុំសាក្សី TCW-79, TCW-155, TCW-160, TCW-298, TCW-347, TCW-380 និង TCW-486។

[109] កាលវិភាគសម្រាប់ឯកសារចុងក្រោយ និងសវនាការដទៃទៀត ក្នុងសំណុំរឿង ០០២/០១ សម្រាប់ការសាកសួរជនជាប់ចោទ និងចម្លើយតបចំពោះសារណា E263 និង E288/1, E288/1/1 ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣, សារអេឡិចត្រូនិករបស់លោកស្រី Susan LAMB កម្មវត្ថុ៖ ការជូនដំណឹងជាមុនអំពីសាក្សីបន្ថែមដែលត្រូវកោះហៅក្នុងសំណុំរឿង ០០២/០១ ជាការឆ្លើយតបចំពោះសំណើរបស់ភាគីនានា ក្នុងកិច្ចប្រជុំរៀបចំសវនាការ E292 ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ *សូមមើលផងដែរ* ឧបសម្ព័ន្ធ II៖ បុគ្គលដែលត្រូវបានស្នើឡើងដោយភាគី ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ប៉ុន្តែជាចុងក្រោយមិនត្រូវបានស្តាប់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ (ត្រូវបានផ្ញើរជាឯកសារថតចម្លងផ្តល់ជូនជាមុន ទៅដល់ភាគីនានា ដោយមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣)។

សម្រេចមិនទទួលយកសំណើរបស់ នួន ជា ដែលសុំឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញនូវសេចក្ដីសម្រេចរបស់ខ្លួន បដិសេធមិនកោះហៅសាក្សីទាំងប្រាំបីរូបនេះ[110]។

38. ពាក់ព័ន្ធទៅនឹងសាក្សីនៅសល់ ១០៣ នាក់ទៀត ដែល នួន ជា ស្នើសុំឱ្យកោះហៅនោះ អង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់ថា នួន ជា ត្រូវបានជូនដំណឹងចាប់តាំងពីខែ មេសា ឆ្នាំ ២០១១ មកថា សហព្រះរាជអាជ្ញាមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីជំនួសឱ្យការស្ដាប់សក្ខីកម្មផ្ទាល់មាត់របស់សាក្សីទាំងនេះ ដែលកំពុងត្រូវបានស្នើឡើងដោយមេធាវីការពារក្ដី។ បន្ទាប់ពីអង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចលើកំណត់ហេតុស្ដាប់ចម្លើយ នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ មក សហព្រះរាជអាជ្ញាបានជូនដំណឹងដល់អង្គជំនុំជម្រះ និងភាគី អំពីបញ្ជីកំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលកែប្រែថ្មី ដែលខ្លួនបានស្នើឡើងក្នុងខែ កក្កដា ឆ្នាំ ២០១២ និង ខែ មេសា ឆ្នាំ ២០១៣[111]។ សេចក្ដីសម្រេចរបស់ នួន ជា ក្នុងការមិនស្នើសុំសាក្សីទាំងនេះ កាលពីពេលមុន បើទោះបីជាខ្លួនទទួលបានការជូនដំណឹងថា កំណត់ហេតុស្ដាប់ចម្លើយសាក្សីទាំងនេះអាចត្រូវបានទទួលយកជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ តាំងពីខែ មេសា ឆ្នាំ ២០១១ ក៏ដោយ មិនមែនជាការយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងការស្វែងរក និងស្នើសុំភស្ដុតាងនេះទេ ជាពិសេសក្នុងដំណាក់កាលចុងក្រោយនៃការជំនុំជម្រះនេះ។ ហេតុដូច្នេះ នួន ជា មិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនោះទេ។ អង្គជំនុំជម្រះសម្រេចបដិសេធលើសំណើនេះ។

39. ទោះជាក្នុងកាលៈទេសៈណាក៏ដោយ អង្គជំនុំជម្រះសូមកត់សម្គាល់ថា លើកលែងតែកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីតែមួយប៉ុណ្ណោះ កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីទាំងអស់ ដែលបានស្នើឡើង

---

[110] ដោយពិចារណាថាវិធានផ្ទៃក្នុង មិនបានចែងពីការពិចារណាឡើងវិញ ទៅលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនោះ អង្គជំនុំជម្រះនេះមិនពិចារណាលើសំណើពាក់ព័ន្ធបញ្ហាដែលខ្លួនបានសម្រេចរួចហើយនោះទេ។ ជាជំនួស ភាគីនានាអាចប្ដឹងសាទុក្ខសេចក្ដីសម្រេចក្នុងពេលវេលាសមស្របមួយ ឬដាក់សំណើថ្មីនៅចំពោះមុខអង្គជំនុំជម្រះ នៅពេលមានយុត្តិកម្មដោយកាលៈទេសៈថ្មី (សេចក្ដីសម្រេចលើសំណើរបស់ អៀង សារី សុំឱ្យពិចារណាឡើងវិញលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ចំពោះសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ព្រមទាំងសំណើបំពេញបន្ថែម E238/11/1 ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១១ កថាខណ្ឌ ៧, *សូមមើលផងដែរ* សំណុំរឿង ០០១ សាលដីកា ជើងទំព័រ ២៨ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៤៩១)។

[111] កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីទាំងអស់ដែលបានស្នើឡើង ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីខែ មេសា ឆ្នាំ ២០១១ លើកលែងតែកំណត់ហេតុចំនួនមួយចេញ កំណត់ហេតុស្ដាប់ចម្លើយទាំងអស់ត្រូវបានដាក់បញ្ចូលទៅក្នុងសំណើខែ កក្កដា ឆ្នាំ ២០១២ របស់ ក.ស.ព (ឯកសារ D108/6/15) ហើយលើកលែងតែចម្លើយចំនួនប្រាំបួនចេញ កំណត់ហេតុស្ដាប់ចម្លើយទាំងអស់ត្រូវបានដាក់បញ្ចូលក្នុងសំណើដែលត្រូវបានកែសម្រួលរបស់ ក.ស.ព ដែលបានដាក់កាលពីខែ មេសា ឆ្នាំ ២០១៣ (ឯកសារ D108/6/15, D232/86, D125/66, E190.1.63, D125/96, D125/116, D25/26, D125/120 និង D125/89) ។

ដោយ នួន ជា ហើយមាននៅក្នុងសំណើកែប្រែថ្មីរបស់សហព្រះរាជអាជ្ញានោះ ត្រូវបានទទួលយក[112]។ ក្នុងករណីដែលកំណត់ហេតុស្តាប់ចម្លើយសាក្សី ដូចជាចម្លើយសាក្សីទាំងនេះជាដើម បានបំពេញតាមលក្ខខណ្ឌនានានោះ អង្គជំនុំជម្រះបានសម្រេចរួចហើយថា ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ និងកិច្ចដំណើរការនីតិវិធីឆាប់រហ័ស ចម្លើយទាំងអស់នេះត្រូវទទួលយក ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ដូច្នេះគឺអនុញ្ញាតឱ្យអង្គជំនុំជម្រះលែងត្រូវការវត្តមានរបស់អ្នកផ្តល់ចម្លើយនៅចំពោះមុខតុលាការ[113]។

### ៤.២.៦. ឧបសគ្គបន្ថែមទៀតចំពោះឱកាសក្នុងការសួរដេញដោល

40. សហព្រះរាជអាជ្ញាស្នើសុំដាក់កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកចំនួន ៣២ នៅក្នុងសំណើកែប្រែថ្មីរបស់សហព្រះរាជអាជ្ញា កាលពីខែ មេសា ឆ្នាំ ២០១៣ ដែលកំណត់ហេតុស្តាប់ចម្លើយ និងប្រតិ-ចារឹកទាំងនេះមានកំណត់នៅក្នុងបញ្ជីខែ មេសា ឆ្នាំ ២០១១ របស់សហព្រះរាជអាជ្ញា ប៉ុន្តែមិនមាននៅក្នុងសំណើ ខែ កក្កដា ឆ្នាំ ២០១២ របស់សហព្រះរាជអាជ្ញាទេ (ឧបសម្ព័ន្ធសម្ងាត់ ខ ផ្នែកទី ៤) [114]។ អង្គជំនុំជម្រះបានបង្គាប់ដល់ភាគីនានាឱ្យដាក់បញ្ជីកែប្រែថ្មីស្តីពីកំណត់ហេតុស្តាប់ចម្លើយសាក្សី និងប្រតិចារឹកដែលស្នើសុំឱ្យទទួលយក ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ត្រឹមថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២[115]។ នៅខែ តុលាឆ្នាំ ២០១២ អង្គជំនុំជម្រះបានណែនាំបន្ថែមដល់សហព្រះរាជអាជ្ញាឱ្យធ្វើការ

---

[112] ឯកសារលេខ IS19.149 ត្រូវបានដកចេញដោយផ្អែកលើមូលដ្ឋានដែលថា សហព្រះរាជអាជ្ញាមិនបានអនុវត្តដោយយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងការបង្ហាញឯកសារនេះ (សូមមើល ផ្នែក ៤.២.៦ និងឧបសម្ព័ន្ធសម្ងាត់ ខ ផ្នែកទី ៤)។

[113] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ២៣-៣៣។

[114] កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំង ៣២ នេះ ត្រូវបានផ្តល់ឱ្យដោយសាក្សីដែលមិនបានមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ហើយដែលមិនបានទទួលយកកាលពីពេលមុន។ អង្គជំនុំជម្រះដឹងអំពីកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកបន្ថែម ដែលត្រូវបានដាក់បញ្ចូលក្នុងឧបសម្ព័ន្ធ ១២ ដែលត្រូវបានកែសម្រួល និង ឧបសម្ព័ន្ធ ១៣ ដែលត្រូវបានកែសម្រួល ប៉ុន្តែមិនមាននៅក្នុងសំណើខែ កក្កដា ឆ្នាំ ២០១២ របស់ក.ស.ព។ ទោះជាយ៉ាងនេះក៏ដោយ កំណត់ហេតុស្តាប់ចម្លើយនិងប្រតិចារឹកទាំងនេះ អាចត្រូវបានផ្តល់ឱ្យដោយសាក្សី ដែលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ និង/ឬ ដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះកាលពីមុនព្រមទាំងទទួលបានលេខ E3។ ស្ថិតក្នុងកាលៈទេសៈបែបនេះ អង្គជំនុំជម្រះពិចារណាថា ភាគីនានាទទួលបានការជូនដំណឹង និងមានឱកាសគ្រប់គ្រាន់សម្រាប់ការជំទាស់ ចំពោះឯកសារទាំងអស់នេះ ទោះបីជាសហព្រះរាជអាជ្ញាមានការយឺតយ៉ាវក្នុងការដាក់ សម្រាប់ឱ្យពិចារណារួមជាមួយលក្ខណៈសម្បត្តិដែលមានកំណត់នៅក្នុងសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ។

[115] សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ៣៤-៣៦, ផ្នែកសម្រេចសេចក្តី។ នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ ដើម្បីជាប្រយោជន៍នៃដំណើរការនីតិវិធីឆាប់រហ័ស អង្គជំនុំជម្រះបានបញ្ជាក់បំភ្លឺថា ភាគីនានាត្រូវបញ្ជាក់យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ អំពីចម្លើយនានាដែលខ្លួនចង់ស្នើសុំ ពាក់ព័ន្ធសំណុំរឿង ០០២/០១ (អនុស្សរណៈខែ កក្កដា ឆ្នាំ ២០១២ កថាខណ្ឌ ៣)។

បង្ហាញឱ្យបានឆាប់បំផុត ថាតើចម្លើយសាក្សីណាខ្លះដែលខ្លួនលែងចង់ស្នើសុំ ហើយអង្គជំនុំជម្រះបង្គាប់ថា រាល់ការជំទាស់ចំពោះសំណើរបស់សហព្រះរាជអាជ្ញា កាលពីខែ កក្កដា ឆ្នាំ ២០១២ ត្រូវដាក់ឱ្យបានមុនថ្ងៃ ២៦ ខែ មេសា ឆ្នាំ ២០១៣[116]។ សហព្រះរាជអាជ្ញាមិនបានបង្ហាញពីចេតនាស្នើសុំដាក់កំណត់ហេតុស្តាប់ចម្លើយសាក្សី លើសពីអ្វីដែលបានកំណត់នៅក្នុងសំណើកាលពីខែ កក្កដា ឆ្នាំ ២០១២ របស់ខ្លួននោះឡើយ។ លើសពីនេះទៀត សហព្រះរាជអាជ្ញាបានបញ្ជាក់អះអាងពីរដងទៀត រួមទាំងការអះអាងបន្ទាប់ពីមានការពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១ ដែលដាក់បញ្ចូលការកាប់សម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរ នៅទួលពោធិ៍ជ្រៃ ថា សំណើខែ កក្កដា ឆ្នាំ ២០១២ របស់សហព្រះរាជអាជ្ញា ដែលរួមបញ្ចូលទាំងសំណើសុំដំណាក់កាលទី១ និងសំណើសុំដំណាក់កាលទី២ នោះ គឺជាបញ្ជីស្នើសុំស្តីពីកំណត់ហេតុស្តាប់ចម្លើយសាក្សី និងប្រតិចារឹកចុងក្រោយ និងអាចប្រើប្រាស់បាន[117]។ ទើបតែនៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៣ គឺជាងប្រាំបីខែ បន្ទាប់ពីដាក់សំណើរបស់សហព្រះរាជអាជ្ញា ខែ កក្កដា ឆ្នាំ ២០១២ និងប្រហែលជាពីរសប្តាហ៍មុនកាលបរិច្ឆេទកំណត់ដែលដាក់ដោយអង្គជំនុំជម្រះសម្រាប់ឱ្យភាគីនានាដាក់ការជំទាស់នោះ ទើបសហព្រះរាជអាជ្ញាបានដាក់សំណើកែប្រែថ្មីរបស់ខ្លួនដែលរួមបញ្ចូលកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកដែលមិនបានស្នើសុំនៅក្នុងសំណើខែ កក្កដា ឆ្នាំ ២០១២ របស់ខ្លួន ប៉ុន្តែសំណើនេះមិនបានកំណត់អត្តសញ្ញាណឯកសារនោះទេ។

41. អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ពាក់ព័ន្ធទៅនឹងឯកសារទាំង ៣២ ដែលបានដាក់បញ្ចូលយឺតនៅក្នុងសំណើកែប្រែថ្មីកាលពីខែ មេសា ឆ្នាំ ២០១៣ នោះ សហព្រះរាជអាជ្ញាមិនបានអនុវត្តដោយមានការយកចិត្តទុកដាក់គ្រប់គ្រាន់នោះទេ ដូច្នេះវាជាការរាំងស្ទះឱកាសក្នុងការសួរដេញដោល ដូចដែលបានតម្រូវដោយវិធាន ៨៧ នៃវិធានផ្ទៃក្នុង។ ជាលទ្ធផល អង្គជំនុំជម្រះបដិសេធសំណើសុំទទួលយកឯកសារទាំងនេះ (ឧបសម្ព័ន្ធសម្ងាត់ ខ ផ្នែកទី ៤)។

42. លើសពីនេះទៀត អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សំណើសុំ D22/3246 របស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានចាត់ចំណាត់ថ្នាក់ថាជាឯកសារ "សម្ងាត់បំផុត" រហូតដល់ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣។ នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធបានស្នើសុំការធ្វើចំណាត់ថ្នាក់ឡើងវិញ ហើយទន្ទឹមនឹងគ្នានោះ ក៏បានដកសំណើកាលពីមុនរបស់ខ្លួន ដែលបាន

[116] អនុស្សរណៈខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ៩ និង ១៤។

[117] សំណើខែ កញ្ញា ឆ្នាំ ២០១២, សំណើខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ៦-៧។ ៥២ / ៤

ស្នើសុំវិធានការការពារ[118]។ អង្គជំនុំជម្រះបានច្រានចោលសំណើសុំវិធានការការពារនេះ កាលពីថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣ ហើយបានកំណត់ចំណាត់ថ្នាក់ឯកសារ D22/3246 ជាឯកសារ "សម្ងាត់" វិញ នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣[119]។ ប្រហែលជាប្រាំខែមុន គឺនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ សហមេធាវីនាំមុខបានធ្វើ "ការសាកសួរយ៉ាងត្រឹមត្រូវ ហើយរង់ចាំការសម្រេចចុងក្រោយទៅលើស្ថានភាពនៃដីកាស្ដីពីវិធានការការពារ" ដើម្បីឲ្យចម្លើយសាក្សីដែល "សម្ងាត់បំផុត" ហើយដែលភាគីផ្សេងទៀតមិនអាចចូលពិនិត្យបាននោះ ត្រូវបានចាត់ចំណាត់ថ្នាក់ឡើងវិញ ឬក៏ត្រូវបានដកចេញពីសំណើកែប្រែថ្មីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី[120]។ ដោយសារតែមិនបានស្វែងរកការចាត់ចំណាត់ថ្នាក់ឡើងវិញ ឬក៏មិនបានស្វែងរកការដកឯកសារ D22/3246 ចេញពីបញ្ជីកែប្រែថ្មីរបស់ខ្លួនស្ដីពីកំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលត្រូវបានស្នើឡើង ឲ្យបានមុនកាលបរិច្ឆេទសម្រាប់សេចក្ដីជំទាស់ជាលាយលក្ខណ៍អក្សរនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ដូចដែលសហមេធាវីនាំមុខបានបញ្ជាក់លើកមុនថាខ្លួននឹងធ្វើនោះ អង្គជំនុំជម្រះយល់ឃើញថា សហមេធាវីនាំមុខមិនបានយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងការបង្ហាញឯកសារ D22/3246 នោះទេ។ ទាំងមេធាវីការពារក្ដី ក៏ដូចជាសហព្រះរាជអាជ្ញាមិនអាចចូលមើលឯកសារទាំងអស់នេះ មុនពេលខ្លួនដាក់សេចក្ដីជំទាស់ និងសារណាពាក់ព័ន្ធទៅនឹងបណ្ដាឯកសារ ដែលបានស្នើសុំដាក់ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ ឬនិយាយតាមពិតទៅគឺមិនអាចចូលមើលរហូតដល់មានការចាត់ចំណាត់ថ្នាក់ឡើងវិញ ចំពោះឯកសារ D22/3246 ដោយអង្គជំនុំជម្រះនៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣។ ដោយមិនមានឱកាសក្នុងការសួរដេញដោលឲ្យមានប្រសិទ្ធភាពនោះ អង្គជំនុំជម្រះសម្រេចបដិសេធសំណើសុំដាក់ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ឯកសារលេខ D22/3246 នេះ (ឧបសម្ព័ន្ធសម្ងាត់ ខ ផ្នែកទី ៥)។

### ៤.២.៧. កំណត់ហេតុស្ដាប់ចម្លើយសាក្សី និងប្រតិចារឹក របស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ

43. សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ បានស្នើសុំដាក់កំណត់ហេតុស្ដាប់ចម្លើយ និងប្រតិចារឹក ចំនួន ២៤៧ របស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។

[118] លិខិតសុំដកចេញសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសុំឲ្យមានវិធានការការពារ E2/21 ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣។

[119] ផ្នែកសម្រេចសេចក្ដីចំពោះសំណើទាំងអស់សុំវិធានការការពារ ដែលត្រូវបានស្នើសុំក្នុងសំណុំរឿង ០០២/០១ ព្រមទាំងចម្លើយតបចំពោះសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យធ្វើការកោះហៅឡើងវិញ ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ហើយនិងដីកាបង្គាប់ឲ្យវាយតម្លៃជាផ្លូវការចំពោះតម្រូវការសម្រាប់វិធានការការពារ (E286), E293 ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៩។

[120] សំណើដែលត្រូវបានកែសម្រួលរបស់ដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ១០។

នៅពេលដែលសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីមកបង្ហាញខ្លួននៅចំពោះមុខ ពេលនោះមេធាវីការពារក្តីមានឱកាសសួរតទល់ជាមួយពួកគាត់ទាក់ទងនឹងចម្លើយ និងប្រតិចារឹក។ ចម្លើយទាំងអស់នេះមិនចាំបាច់បំពេញតាមលក្ខណៈវិនិច្ឆ័យ ដូចមានកំណត់ក្នុងសេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយនោះទេ។ ប៉ុន្តែ ចម្លើយទាំងនោះគ្រាន់តែត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពអាចទទួលយកបានជាទូទៅដូចមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងប៉ុណ្ណោះ។

44. អង្គជំនុំជម្រះជឿជាក់ថា កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំងនេះរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ មានភាពពាក់ព័ន្ធ និងអាចជឿជាក់បាន*ជាបឋម*។ លើសពីនេះ ទៀត ដើម្បីជាប្រយោជន៍យុត្តិធម៌ កំណត់ហេតុស្តាប់ចម្លើយបែបនេះត្រូវទទួលការពិចារណា ជាមួយនឹងភស្តុតាងដទៃទៀតរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី។ ដោយសារតែកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំងអស់នេះ មិនទាន់បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះក្នុងពេលនេះសម្រេចទទួលយកចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះនឹងវាយតម្លៃនៅពេលបញ្ចប់កិច្ចដំណើរការនីតិវិធី តាមសភាពជាក់ស្តែង ចំពោះតម្លៃនៃភស្តុតាងរបស់កំណត់ហេតុស្តាប់ចម្លើយទាំងអស់នេះ (ឧបសម្ព័ន្ធសម្ងាត់ ក ផ្នែកទី ៥)។

**តាមសម្អាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**សម្រេចអនុញ្ញាតតាមសំណើ** របស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ដែលស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹក ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធសម្ងាត់ ក ។

**សម្រេចបដិសេធ** សំណើរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ដែលស្នើសុំដាក់នៅចំពោះមុខអង្គ-ជំនុំជម្រះនូវកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹក ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធសម្ងាត់ ខ ។

**សម្រេចបដិសេធ** សំណើរបស់ នួន ជា ដែលសុំឱ្យកោះហៅសាក្សីបន្ថែម ១១ នាក់ (ឯកសារ E291/2)។

**សូមរំឭក** ដល់ភាគីទាំងអស់ថា រាល់ភស្តុតាងទាំងអស់ត្រូវតែមានជាបីភាសាផ្លូវការរបស់ អ.វ.ត.ក យ៉ាងយូរបំផុតត្រឹមពេលដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល។

**ប្រកាសថា** លក្ខណៈវិនិច្ឆ័យដូចបានកំណត់ក្នុងសេចក្តីសម្រេចនេះ ព្រមទាំងសារណា និងការជំទាស់នានា ត្រូវទទួលបានការពិចារណាពីអង្គជំនុំជម្រះ នៅពេលវាយតម្លៃពីតម្លៃ និងទម្ងន់ ប្រសិនបើមានចំពោះកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំងអស់ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងសាលក្រម។

**រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣**

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**